# ព្រឹត្តិបត្រមេធាវី
# លេខ ២២
# ខែ កក្កដា-កញ្ញា ឆ្នាំ ២០១៩

រក្សាសិទ្ធិ © 2019 គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

មតិដែលសំដែងនៅក្នុងព្រឹត្តិបត្រនេះ គឺជាមតិរបស់អ្នកនិពន្ធផ្ទាល់ ហើយមិនបញ្ជាំងនូវទស្សនៈរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឡើយ។

ស្របតាមគោលការណ៍សេរីភាពនៃការបញ្ចេញមតិ ដែលជាគោលការណ៍គ្រឹះ និងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីគាំទ្រឱ្យមានភាពចម្រុះនៃមតិនានា។

សូមរក្សាសិទ្ធិ © ដោយអនុលោមតាមច្បាប់ស្ដីពី "សិទ្ធិអ្នកនិពន្ធ និងប្រហាក់ប្រហែល" ដែលត្រូវបានប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣ ហើយរាល់ការថតចម្លងឡើងវិញ ដោយគ្មានការអនុញ្ញាតពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាត្រូវហាមឃាត់។

ទំព័រ

# មាតិកា

**សារពីប្រធានគណៈមេធាវី** ....................................................................... III

**ព្រហ្មទណ្ឌ**

**តុលាការព្រហ្មទណ្ឌអន្តរជាតិ ( ខ្លឹមសារសង្ខេប )** ....................................... 1

១. សេចក្តីផ្តើម ....................................................................... 1

២. សមត្ថកិច្ច និងយុត្តាធិការ ....................................................... 1

៣. បញ្ហាប្រឈម ....................................................................... 5

៤. សង្ខេប ............................................................................... 9

**ច្បាប់ធនាគារ**

**តួនាទី និងការទទួលខុសត្រូវរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ** ........................................................................ 13

១. សេចក្តីផ្តើម ....................................................................... 13

២. និយមន័យ និងគុណវុឌ្ឍិរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ .................... 15

២.១. និយមន័យ ....................................................................... 15

២.២.គុណវុឌ្ឍិរបស់អភិបាល និងសមាសភាពក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ........................................................................ 16

២.២.១.គុណវុឌ្ឍិរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ .................... 16

២.២.២.សមាសភាពក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ........... 19

៣. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ....... 20

៣.១ តួនាទី និងភារកិច្ចរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ........................ 20

៣.២. ការទទួលខុសត្រូវរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ .................. 23

៣.២.១. ការទទួលខុសត្រូវរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្រោមក្របខណ្ឌច្បាប់ពាណិជ្ជកម្ម ........................................................ 23

៣.២.២. ការទទួលខុសត្រូវរបស់អភិបាលនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក្រោមក្របខណ្ឌច្បាប់គ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ .......................... 29

៤. សេចក្តីសន្និដ្ឋាន ........ 33

## សកម្មភាពរបស់គណៈមេធាវី

១.ទំនាក់ទំនងជាតិ និងអន្តរជាតិ ........ 37
១.១.ទំនាក់ទំនងជាតិ ........ 37
១.២.ទំនាក់ទំនងអន្តរជាតិ ........ 38
២.ការផ្សព្វផ្សាយច្បាប់តាមរយៈសិក្ខាសាលា ........ 41
៣.កិច្ចប្រជុំបុគ្គលិក ........ 43
៤.កិច្ចប្រជុំគណៈកម្មការជំនាញ ........ 49
៥. ការផ្សព្វផ្សាយតាមទូរទស្សន៍ ........ 51
៦. ផ្សេងៗ ........ 53

# សារពីប្រធានគណៈមេធាវី



គណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជាមានកិត្តិយស សូមបោះពុម្ពបន្តនូវ ព្រឹត្តិបត្រមេធាវីលេខ ២២ សម្រាប់ត្រីមាសទី ៣ ខែកក្កដា-កញ្ញាឆ្នាំ២០១៩។ព្រឹត្តិបត្រមេធាវីនេះ បានសម្រេចឡើងដោយ ការប្រឹងប្រែង លះបង់ពេលវេលាដ៏មានតម្លៃរបស់អ្នកនិពន្ធ នីមួយៗ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍របស់គាត់។ តាងនាមឱ្យគណៈមេធាវី ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកនិពន្ធ ដែលបានរួមចំណែក វិភាគទានអត្ថបទរបស់ខ្លួន។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់លោកអគ្គលេខាធិការ លោកអគ្គលេខាធិការរងប្រធាន បុគ្គលិក និងអ្នកស្ម័គ្រចិត្តនៃនាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយនៃគណៈមេធាវីដែលបានខិតខំរៀបចំពិនិត្យ និងសម្រួលអត្ថបទ និងការបោះពុម្ពព្រឹត្តិបត្រលេខនេះ។

ព្រឹត្តិបត្រលេខនេះប្រមូលផ្តុំនូវអត្ថបទនៅក្នុងវិស័យនានា ដូចជា ព្រហ្មទណ្ឌ និងច្បាប់ធនាគារ ជាដើម។ បន្ថែមលើការផ្សាយនូវអត្ថបទច្បាប់ ព្រឹត្តិបត្រមេធាវីបានផ្តល់ព័ត៌មានស្តីពីសកម្មភាពនៃគណៈមេធាវី ដើម្បីឲ្យសហភាតាជាមេធាវីបានជ្រាបពីកិច្ចដំណើរ ការនៃគណៈមេធាវី។ គណៈមេធាវីនឹងស្វះស្វែងទាក់ទងមេធាវី និងអ្នកច្បាប់ដទៃទៀត ដើម្បីពង្រីកការចែករំលែកនូវចំណេះដឹងនៅក្នុងវិស័យដទៃទៀត នៅក្នុងការផ្សាយលើកក្រោយៗ។

ការបោះពុម្ពផ្សាយព្រឹត្តិបត្រមេធាវីនេះជាការឆ្លើយតបទៅនឹង**ទិសដៅទី ២ “ពង្រឹង និងការពារវិជ្ជាជីវៈ”** **នៃផែនការសកម្មភាពនៃគណៈមេធាវី** ដែលបានអនុម័តដោយក្រុមប្រឹក្សា-គណៈមេធាវី។

ខ្ញុំសង្កេតឃើញថា នៅក្នុងសហគមន៍អ្នកច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងមានអ្នកជំនាញខាងច្បាប់ជាច្រើន ដែលបានសរសេរផ្សព្វផ្សាយសៀវភៅសិក្សា ដើម្បីបម្រើសេចក្តីត្រូវការនៃអ្នកសិក្សាច្បាប់។ ទោះបីមិនមែនជាអ្នកជំនាញក៏ដោយ ខ្ញុំសូមលើកទឹកចិត្ត

ដល់មេធាវី និងអ្នកសិក្សាទូទៅចូលរួមវិភាគទានអត្ថបទ ដើម្បីចុះផ្សាយក្នុងព្រឹត្តិបត្រមេធាវី។ គណៈមេធាវីស្វាគមន៍ជានិច្ចដល់ការចូលរួមចែករំលែកអត្ថបទរបស់ខ្លួននៅក្នុងព្រឹត្តិបត្រនេះ។ ចំពោះអ្នកដែលមានបំណិនខាងសរសេរមានកម្រិត គណៈមេធាវីមានក្រុមបណ្ណាធិការមួយ ដែលនឹងជួយផ្តល់ការណែនាំដល់អ្នកចូលរួម និងជួយកែសម្រួលអត្ថបទ។ គោលដៅនៃការបង្កើតព្រឹត្តិបត្រនេះ មិនត្រឹមតែផ្សព្វផ្សាយអត្ថបទនៃអ្នកនិពន្ធជើងចាស់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកស្ទួយបំណិនខាងសរសេរដល់អ្នកនិពន្ធជំនាន់ក្រោយផងដែរ។

ខ្ញុំយល់ឃើញថា ថ្វីបើក្រុមបណ្ណាធិការបានផ្ចិតផ្ចង់ក្នុងការធ្វើឲ្យព្រឹត្តិបត្រទទួលបានគុណភាពមួយដ៏ខ្ពស់ក៏ដោយ ការខ្វះខាតគង់តែជៀសមិនផុត។ ដើម្បីជ្រោមជ្រែងឲ្យព្រឹត្តិបត្រនេះមានគុណភាពកាន់តែប្រសើរ ខ្ញុំសូមអំពាវនាវដល់អ្នកអានមេត្តាសរសេរតប និងរិះគន់ស្ថាបនា ធ្វើអត្ថាធិប្បាយ ឬបំពេញបន្ថែមទៅលើអត្ថបទនីមួយៗដែលបានបោះពុម្ពផ្សាយ។ ខ្ញុំសង្ឃឹមថា សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីនឹងបានរីករាយក្នុងការអានព្រឹត្តិបត្រមេធាវីលេខនេះ។

ចំពោះការចូលរួមវិភាគអត្ថបទ សូមធ្វើការទាក់ទងមកការិយាល័យគណៈមេធាវីដោយផ្ទាល់តាមរយៈលោកមេធាវី **ភុយ នាម** តាមអ៊ីម៉ែល neam130@bakc.org.kh និងលោកមេធាវី **ទ៉ា សំរិត** តាមអ៊ីម៉ែល samrit@bakc.org.kh ក៏បាន។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីទាំងអស់ សូមជួបតែជោគជ័យគ្រប់ប្រការ។

សូមអរគុណ!

ថ្ងៃចន្ទ ២កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩



**សួន វិសាល**

ប្រធានគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា

# ព្រហ្មទណ្ឌ

# តុលាការព្រហ្មទណ្ឌអន្តរជាតិ ( ខ្លឹមសារសង្ខេប )

### ដោយ បណ្ឌិត មាស ប៊ូរ៉ា*

## ១. សេចក្តីផ្តើម

នៅកម្រិតអន្តរជាតិ មានយន្តការដោះស្រាយជម្លោះជាច្រើន រួមបញ្ចូលផងដែរ តុលាការក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ (Criminal Justice)។ តុលាការព្រហ្មទណ្ឌអន្តរជាតិ (International Criminal Court: ICC) ត្រូវបានបង្កើតក្នុងឆ្នាំ១៩៩៨។ មានអ្នកស្រាវជ្រាវខ្លះ ច្រឡំសមត្ថកិច្ចរបស់តុលាការនេះ នឹងតុលាការយុត្តិធម៌អន្តរជាតិ។ អត្ថបទសង្ខេបខ្លីនេះ ព្យាយាមស្រាយបំភ្លឺបញ្ហានេះ ព្រមទាំងបង្ហាញពីបច្ចុប្បន្នភាពខ្លះៗ ដូចជា បញ្ហាការស្នើសុំដកខ្លួនរបស់ហ្វីលីពីន ក្រោយពីប្រធានាធិបតីខ្លួន បានជាប់បណ្តឹងនៅចំពោះមុខ ICC ពាក់ព័ន្ធនឹង ការបង្ក្រាបជនសង្ស័យប្រព្រឹត្តបទល្មើសគ្រឿងញៀន។

## ២. សមត្ថកិច្ច និងយុត្តាធិការ

តុលាការព្រហ្មទណ្ឌអន្តរជាតិ ("តពអ") ជាស្ថាប័នអចិន្ត្រៃយ៍[1] តែមិនមែនជាស្ថាប័នរបស់ អង្គការសហប្រជាជាតិទេ។[2] វាជាស្ថាប័ន បង្កើតតាមសន្ធិសញ្ញារ៉ូម ក្រោមការគ្រប់គ្រងចាត់ចែង របស់សន្និសីទរបស់រដ្ឋភាគី (Conference of State Parties)។[3] "តពអ" មានសមត្ថកិច្ច លើបទល្មើសក្រោមច្បាប់អន្តរជាតិមាន បទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បទឧក្រិដ្ឋកម្មសង្គ្រាម ព្រមទាំងបទឧក្រិដ្ឋឈ្លានពាន (Aggression)។[4] ទោះបីជាយ៉ាងនេះក្តី បទឧក្រិដ្ឋចុងក្រោយ ទើបនឹងអាចត្រូវបានយកមកអនុវត្តក្នុងឆ្នាំ២០១៨ ក្រោយការធ្វើវិសោធនកម្មលក្ខន្តិកៈ ក្នុងឆ្នាំ២០១០។ មានមូលហេតុជាច្រើននៅពីក្រោយការពន្យានេះ

---

* លោកមេធាវី មាស ប៊ូរ៉ា ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលមជ្ឈត្តករពាណិជ្ជកម្ម និងសាស្ត្រាចារ្យច្បាប់។

[1] ប្រវត្តិនៃ ICC, https://www.icc-cpi.int/about (ចូលមើលក្នុងថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៩)។

[2] Courts and Tribunals, https://research.un.org/en/docs/law/courts(ចូលមើលក្នុងថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៩)។

[3] មាត្រា ១២៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម, UN General Assembly, *Rome Statute of the International Criminal Court (last amended 2010)*, 17 July 1998, ISBN No. 92-9227-227-6, available at: https://www.refworld.org/docid/3ae6b3a84.html [accessed 12 November 2019](Rome Statute)។

[4] មាត្រា ១៥ *(bis)* នៃលក្ខន្តិកៈទីក្រុងរ៉ូម។

ដោយសារ ការផ្តល់និយមន័យនៅមិនទាន់មានការឯកភាព។[5] ប្រទេសមហាអំណាច ដែលមានលទ្ធភាពក្នុងការឈ្លានពានប្រទេសដទៃ មិនចង់ឲ្យមានបទឧក្រិដ្ឋប្រភេទនេះ ក្នុងសមត្ថកិច្ចរបស់ "តពអ"។[6]

តាមទ្រឹស្តីមិនប្រតិសកម្មនៃច្បាប់ (Non-Retroaction of Law) "តពអ" មានសមត្ថកិច្ចចំពោះបទឧក្រិដ្ឋ ដែលកើតមានក្រោយពេលដែលលក្ខន្តិកៈទីក្រុងរ៉ូមបង្កើត "តពអ" ចូលជាធរមានសម្រាប់ប្រទេសដែលទទួលយកសមត្ថកិច្ចរបស់"តពអ"[7] និងមានសមត្ថកិច្ចលើជនល្មើសដែលមានអាយុលើសពី១៨ ឆ្នាំ។[8]

សូមបញ្ជាក់ថា "តពអ" ជាយន្តការដាក់ការទទួលខុសត្រូវលើបុគ្គល (Individual Criminal Liability) មិនមែនដាក់ការទទួលខុសត្រូវលើរដ្ឋ ដោយសារជាទ្រឹស្តី រដ្ឋមិនអាចប្រព្រឹត្តបទព្រហ្មទណ្ឌទេ ហើយគេពិបាកដាក់គុករដ្ឋផងដែរ។[9] ជាក់ស្តែង អំពើឈ្លានពាន ឧទាហរណ៍ សង្គ្រាមឈ្លានពាន ជាទង្វើរបស់រដ្ឋ ពីព្រោះសភាជាអ្នកអនុម័តឲ្យធ្វើសង្គ្រាម។[10] ក្នុងនោះ ប្រមុខរដ្ឋាភិបាល មេបញ្ជាការ ដែលចូលរួមក្នុងការធ្វើសង្គ្រាម នឹងទទួលខុសត្រូវសម្រាប់អំពើដោយឡែករបស់ខ្លួន នៅចំពោះមុខ "តពអ"។ ដោយឡែកប្រទេសដទៃ ដែលរងគ្រោះដោយសារសង្គ្រាមនោះ អាចដាក់រដ្ឋបង្កសង្គ្រាម ទទួលខុសត្រូវ (State Responsibility) តាមរយៈការប្តឹងទៅយន្តការផ្សេងដូចជា តុលាការយុត្តិធម៌អន្តរជាតិ (International Court of Justice)។[11] ទោះបីជាយ៉ាងនេះក្តី វាមិនមែនជាការងារងាយស្រួលទេ។[12]

---

[5] History, https://en.wikipedia.org/wiki/Crime_of_aggression

[6] ICC crime of aggression comes into effect without key signatures, https://www. the guardian.com/law/2018/jul/17/icc-crimeof-aggression-comes-into-effect-without-key-signatories-uk-law-war

[7] មាត្រា ១១ នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3។

[8] មាត្រា ២៦ នៃលក្ខន្តិកៈទីក្រុងរ៉ូម , *supra* note 3។

[9] "បទឧក្រិដ្ឋប្រឆាំងនឹងច្បាប់អន្តរជាតិ ត្រូវបានប្រព្រឹត្តដោយមនុស្ស មិនមែនដោយអង្គភាពអរូបីយ ហើយមានតែការដាក់ទោសបុគ្គលដែលប្រព្រឹត្តទេ ទើបបទប្បញ្ញត្តិនៃច្បាប់អន្តរជាតិ ត្រូវបានអនុវត្ត" បុគ្គលជាប្រធាននៃច្បាប់អន្តរជាតិ ក្នុងយុត្តិសាស្ត្ររបស់តុលាការយុត្តិធម៌អន្តរជាតិ, 2010, p. 5. Alain Pellet, *Can a State Commit a Crime? Definitely, Yes!*, 10(2) European Journal of International Law, 1999, 425-434.

[10] មាត្រា ២៤ ថ្មី, ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ ១៩៩៣។

[11] ឧទាហរណ៍បណ្តឹងរបស់ប្រទេស យូហ្គោស្លាវីប្រឆាំងនឹងបារាំង ទៅតុលាការយុត្តិធម៌អន្តរជាតិ ពាក់ព័ន្ធការប្រើកំលាំងដោយ ប្រទេសនេះ ក្នុងក្របខ័ណ្ឌ NATO, Legality of Use of Force (Serbia and Montenegro v. France) https://www.icj-cij.org/en/case/112.

បុគ្គលត្រូវបានទទួលខុសត្រូវ លើបទឧក្រិដ្ឋទាំងបួនខាងលើ ដោយសារបានចូលរួម បញ្ជា ជួយ និងតាមទម្រង់សហឧក្រិដ្ឋកម្មរួម (Joint Criminal Enterprise: JCE)។ ជាទម្រង់មួយ ដ៏ចម្រូងចម្រាស់ សូម្បីនៅមុខ អង្គជុំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អវតក"[13]ដែលនាំឲ្យមានការសរសេរយ៉ាងច្បាស់ក្នុងលក្ខន្តិកៈរ៉ូមៈ"ក្នុងមធ្យោបាយណាមួយចូលរួមក្នុងការប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្ត នៃបទឧក្រិដ្ឋ ដោយក្រុមមនុស្ស ធ្វើសកម្មភាព តាមគោលបំណងរួម..."។[14]

ទោះបីបទឧក្រិដ្ឋបានកើតឡើង ប្រព្រឹត្តិដោយបុគ្គលអាយុលើស១៨ឆ្នាំក្តី ក៏ "តពអ" ត្រូវពិចារណាលើកត្តាជាបន្ថែមទៀត ដូចជាបទឧក្រិដ្ឋកើតឡើងក្នុងដែនដីរដ្ឋជាភាគី[15] ឬប្រព្រឹត្ត ដោយប្រជាពលរដ្ឋនៃរដ្ឋជាភាគី[16] ព្រមទាំងការដែលរដ្ឋភាគីមិនចាត់វិធានការស៊ើបអង្កេត ឬ វិន្និច្ឆ័យសេចក្តី ទើប"តពអ" លូកដៃចូលតាមគោលការណ៍បំពេញបន្ថែម (Principle of Complementary)។[17]

គោលការណ៍នេះ តម្រូវថាប្រសិនបើតុលាការរដ្ឋមានសមត្ថភាព ឆន្ទៈពិតប្រាកដ ក្នុងការស៊ើបអង្កេតស្វែងរកយុត្តិធម៌ "តពអ" នឹងមិនធ្វើការស៊ើបទេ។ ក៏ប៉ុន្តែ ក្នុងតុលាការរដ្ឋមានដំណើរស៊ើបអង្កេតរួច ផ្ទាកទៅវិញ ក្នុងចេតនាលាក់បំបាំងការពិត "តពអ" នឹងលូកដៃយករឿងមកពិនិត្យវិញ។[18] ស្រដៀងគ្នានេះ នៅពេល "តពអ" កំពុងដំណើរក្តី ហើយតុលាការរដ្ឋអាចស្នើ

---

[12] តុលាការយុត្តិធម៌អន្តរជាតិ អាចទទួលនិងពិនិត្យបណ្តឹងរដ្ឋ ប្រឆាំងរដ្ឋ ក្នុងករណីដែលរដ្ឋទាំងពីរទទួលស្គាល់សមត្ថកិច្ចរបស់ខ្លួនក្នុងការពិចារណា និងសម្រេចលើរឿងក្តី, មាត្រា ៣៦ នៃលក្ខន្តិកៈ ICJ United Nations, *Statute of the Internatio nal Court of Justice*, 18 April 1946, available at: https://www.refworld.org/docid/3deb4b9c0.html [accessed 25 April 2019]

[13] សូមមើលសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, D97/15/9 (public), ២០ ខែ ឧសភា ឆ្នាំ ២០១០។

[14] In any other way contributes to the commission or attempted commission of such a crime by a group of persons acting with a common purpose, មាត្រា ២៥ (៣.ឃ)។

[15] មាត្រា ១២នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3។

[16] មាត្រា ១២នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3។

[17] បុព្វកថា និងមាត្រា ២ នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3។ សូមមើល Linda E. Carter, The Principle of Complementarity and the International Criminal Court: The Role of Ne Bis in Idem, 8 Santa Clara J.Int'l L. 165 (2010).

[18] មាត្រា ១៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3។

សុំឲ្យ "តពអ" បញ្ជូនរឿងទៅតុលាការរដ្ឋវិញ។[19] ទោះបីជាយ៉ាងនេះក្តីវាទំនងជាស្មុគ្រស្មាញ ហើយពុំទាន់កើតមានឡើយកន្លងមក។

ដំណើរការនៃការស៊ើបអង្កេត ដោយ "តពអ" ចាប់ផ្តើមពីការផ្តួចផ្តើមរបស់រដ្ឋអាជ្ញាខ្លួនឯងផ្ទាល់ តាមព័ត៌មានដែលបានទទួល[20] ឬតាមបណ្តឹងរបស់បុគ្គល អង្គការរដ្ឋជាភាគី[21] និងជាចុងក្រោយ តាមការបញ្ជូនពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។[22] រដ្ឋអាជ្ញាមានឯករាជ្យភាព និងឆន្ទានុសិទ្ធិ អាស្រ័យហេតុនេះ គាត់អាចធ្វើការអង្កេតជាបឋម (Preliminary Investigation) មុនឈានទៅ រកការស៊ើបអង្កេតជាផ្លូវការ នាំទៅរកការស្នើចាប់បញ្ជូនខ្លួន និងឃុំខ្លួនជនសង្ស័យ ដែលតម្រូវឲ្យមានការឯកភាព ឬអនុញ្ញាតពីអង្គបុរេជំនុំជម្រះ (Pre-Trial Chamber)។[23]

រដ្ឋអាជ្ញានឹងចាត់ធ្វើការស៊ើបអង្កេតតាមបណ្តឹងរបស់រដ្ឋ និងបុគ្គល សម្រាប់តែបទល្មើសកើតក្នុងដែនដី ឬដោយប្រជាពលរដ្ឋរបស់រដ្ឋជាភាគី។ ក៏ប៉ុន្តែ ករណីបញ្ជូនដោយក្រុមប្រឹក្សាសន្តិសុខ ធ្វើឡើងសម្រាប់ករណីទាំងអស់ទោះបី បទល្មើស កើតឡើងក្នុងរដ្ឋមិនមែនជាភាគីនៃលក្ខន្តិកៈរ៉ូម។ ជាក់ស្តែង ករណីស្ថានភាពក្នុងប្រទេសស៊ូដង់ ដែលប្រទេសនេះ មិនមែនជាភាគីនៃ លក្ខន្តិកៈ ទីក្រុងរ៉ូម។[24] ករណីនេះ ក៏កើតមានដោយកម្រដែរ ដោយសារវាតម្រូវឲ្យមានការឯកភាពរបស់សមាជិកអចិន្ត្រៃយ៍របស់ក្រុមប្រឹក្សាសន្តិសុខ។[25] ក្រុមប្រឹក្សាសន្តិសុខ ក៏អាចផ្អាកនីតិវិធីនេះឡើងវិញដែរ ប្រសិនបើគិតថា វានាំឲ្យមានបញ្ហាសន្តិភាព ដែលជាសមត្ថកិច្ចរបស់ខ្លួន។[26] នេះនាំឲ្យមានការរិះគន់អំពីកង្វះឯករាជ្យភាពរបស់ "តពអ" ដោយសារការអន្តរាគមរបស់ក្រុមប្រឹក្សាសន្តិសុខ ដែលគេអះអាងថា ជាអំណាចនីតិប្រតិបត្តិ ជារដ្ឋាភិបាលនៃពិភពលោក។[27]

---

[19] International Criminal Court , Questions and Answers on the International Criminal Court, http://www.iccnow.org/documents/FS_ICC_QA.pdfp.4.

[20] មាត្រា ១៥ នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3។

[21] មាត្រា ១៤ នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3។

[22] មាត្រា ១៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3។

[23] មាត្រា ១៥ (៣)នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3។

[24] Situation in Darfur, Sudan, ICC-02/05, https://www.icc-cpi.int/darfur

[25] មាត្រា ១៦នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3។

[26] មាត្រា ១៦នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3។

[27] Hemi Mistry, the UN Security Council and the International Criminal Court, 2012, p.3.

រដ្ឋអាជ្ញាមានសិទ្ធិ និងអំណាចស្នើសុំឲ្យរដ្ឋជាភាគីសហការចាប់បញ្ជូនជនសង្ស័យមក "តពអ"។[28] ដំណើរកាត់វិនិច្ឆ័យសេចក្តីចំណាយពេលវេលាច្រើន ដោយសារបញ្ហានីតិវិធីតាមផ្លូវច្បាប់តម្រូវ ដូចជាការធានានូវសិទ្ធិសេរីភាពរបស់ជនសង្ស័យ[29] រួមទាំងសិទ្ធិប្តឹងឧទ្ធរណ៍ទៅអង្គជំនុំជម្រះជាន់ខ្ពស់ (Appellate Chamber)។[30] "តពអ" ប្រើប្រាស់នីតិវិធីចម្រុះ កំមិនឡូ និង ស៊ីវិលឡូ។[31] នៅពេលដែលជនសង្ស័យត្រូវបានរកឃើញថា មានពិរុទ្ធភាព ពិរុទ្ធជនត្រូវបានដាក់ពន្ធនាគារនៅក្នុងប្រទេសជាភាគី ដែលព្រមទទួលតាមការព្រមព្រៀងរវាង រដ្ឋនោះ និង "តពអ"។[32]

## ៣. បញ្ហាប្រឈម

មានបញ្ហា និងឧបសគ្គជាច្រើន ដែល "តពអ" បានប្រឈម។ អ្វីចម្បង គឺការខ្វះការសហការពីរដ្ឋជាភាគី។ "តពអ" មិនមានមន្ត្រីនគរបាលយុត្តិធម៌សម្រាប់អនុវត្តដីកាទេ។ អ្វីៗត្រូវការសហការពីរដ្ឋជាភាគី ក្នុងទម្រង់ជាការអនុវត្តកាតព្វកិច្ច។[33] "តពអ" មិនមានវិធានការមានប្រសិទ្ធភាព ក្នុងការបង្ខំឲ្យរដ្ឋភាគីអនុវត្តតាមកាតព្វកិច្ចដែរ។ ជាក់ស្តែង ប្រទេសអាហ្វ្រិកខាងត្បូង ដែលជាភាគីខកខានមិនបានឃាត់ និងចាប់ខ្លួន អតីតប្រធានាធិបតីស៊ូដង់ខាងត្បូង Omar al-Bashir មក "តពអ" ទេ នៅពេលប្រធានាធិបតីរូបនេះ មានវត្តមានលើដែនដីខ្លួន។[34]

[28] ផ្នែកទី ៩ ស្តីពី ជំនួយផ្នែកតុលាការ និង សហប្រតិបត្តិការអន្តរជាតិ លក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3.។

[29] មាត្រា ៦៧ និង៦៨ នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3។

[30] មាត្រា ៣៩ នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3។

[31] Gilbert Bitti, Two Bones of Contention Between Civil and Common Law: the Record of the Proceedings and the Treatment of a *Concursus Delictorum*, p. 288, https://www.legal-tools.org/doc/b7b81a/

[32] មាត្រា ១០៣ នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3.។ ឧទាហរណ៍ ICC បានចុះកិច្ចព្រមព្រៀងជាមួយប្រទេសហ្វាំងឡង់, Agreement between the International Criminal Court and the Government of the Republic of Finland on the Enforcement of Sentences of the International Criminal Court, ICC-PRES/07-01-11, entry into Force 24 April 2011.

[33] Judge Sang-Hyun Song, Past Achievements and Future Challenges of the ICC, Keynote speech for the 20th Anniversary of the Rome Statute, p.2

[34] នេះនាំឲ្យ អង្គបុរេជំនុំជម្រះ ២ ចេញសេចក្តីសម្រេចមួយ អះអាងថា អាហ្វ្រិកខាងត្បូងខកខានក្នុងការសហការ ក៏ប៉ុន្តែមិនសម្រេចបញ្ជូនរឿងនេះទៅ កិច្ចប្រជុំរបស់រដ្ឋជាភាគីនៃលក្ខន្តិកៈទីក្រុងរ៉ូមទេ, Pre-Trial Chamber II, Decision under article 87(7) of the Rome Statute on the non-compliance by South Africa with

ស្ថានភាពប្រទេសស៊ូដង់ ត្រូវបានបញ្ជូនដោយក្រុមប្រឹក្សាសន្តិសុខ។ តាមខ្លឹមសារនៃច្បាប់ធម្មនុញ្ញមាត្រា១០៣ និងជំពូក៧[35] រដ្ឋទាំងអស់ត្រូវតែអនុវត្តតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខ មានន័យថា មានកាតព្វកិច្ចចាប់បញ្ជូន លោក Omar al-Bashir តែជាក់ស្តែង លោក Omar al-Bashir នៅតែមានសេរីភាពដើរហើរ ជាពិសេសក្នុងតំបន់ទ្វីបអាហ្វ្រិក។

គេអាចអះអាងថា ដោយសារតែ លោក Omar al-Bashir មានអភ័យឯកសិទ្ធិប្រមុខរដ្ឋ។ នេះមិនត្រឹមត្រូវទេ ពីព្រោះមាត្រានៃលក្ខន្តិកៈទីក្រុងរ៉ូម បាននិយាយច្បាស់ថា អភ័យឯកសិទ្ធិមិនត្រូវជារបាំងនៃការចោទប្រកាន់ទេ។[36] បន្ថែមពីលើនេះ លក្ខន្តិកៈទីក្រុងរ៉ូម មិនអនុញ្ញាតឲ្យមានការចុះខរក្សាសិទ្ធិទេ។ ដូចនេះ ប្រសិនបើ រដ្ឋចូលជាភាគី រដ្ឋត្រូវអនុវត្តតាមកាតព្វកិច្ចទាំងអស់មានចែងក្នុងលក្ខន្តិកៈនេះ។[37]អភ័យឯកសិទ្ធិមិនអាចរារាំងការចោទប្រកាន់បទឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិទេ។ "អវតក" បានបញ្ជាក់ច្បាស់ ផងដែរលើបញ្ហានេះ។[38]

បញ្ហាអភ័យឯកសិទ្ធិ ជាឧបសគ្គ ប្រសិនបើយោងដល់មាត្រា៩៨។[39] "តពអ" ជាស្ថាប័នអន្តរជាតិ ដែលត្រូវតែគោរពផងដែរនូវវិធានច្បាប់អន្តរជាតិ សម្រាប់ជាគំរូដល់ស្ថាប័នដទៃ។ តាមមាត្រានេះ "តពអ" មិនអាចបង្ខំឲ្យរដ្ឋមិនមែនជាភាគី ចាប់បញ្ជូនជនសង្ស័យដែលស្ថិតក្នុងដែនដីរបស់ខ្លួន មក "តពអ" ទេ ដោយសារ រដ្ឋមិនមែនជាភាគី មិនមានកាតព្វកិច្ច និងរដ្ឋនេះត្រូវគោរពកាតព្វកិច្ច ផ្តល់អភ័យឯកសិទ្ធិដល់មេដឹកនាំ(ជនសង្ស័យ) តាមសន្ធិសញ្ញាផ្សេងទៀត។[40]

---

the request by the Court for the arrest and surrender of Omar Al-Bashir, No.: ICC-02/05-01/09, 6 July 2017, p.53.

[35] ក្នុងពេលមានទំនាស់រវាងកាតព្វកិច្ចរបស់សមាជិកអង្គការសហប្រជាជាតិក្រោមធម្មនុញ្ញនេះ ជាមួយនឹងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀត កាតព្វកិច្ចក្រោមធម្មនុញ្ញ នឹងមានឧត្តមានុភាព. Also, see articles 43 and 38, see United Nations, *Charter of the United Nations*, 24 October 1945, 1 UNTS XVI, available at: https://www.refworld.org/docid/3ae6b3930.html [accessed 25 April 2019

[36] Robert Uerpmann, *Immunities before International Criminal Courts*, in Bartlomiej Krzan (ed.), Prosecuting International Crime, 2016, p.2.

[37] *មិនមានខរក្សាសិទ្ធិមិនអនុវត្ត ត្រូវបានអនុញ្ញាតឡើយដល់លក្ខន្តិកៈនេះ* មាត្រា ១២០នៃលក្ខន្តិកៈទីក្រុងរ៉ូម, *supra* note 3.

[38] អង្គជំនុំជម្រះ សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ អៀង សារី តាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង (គោលការណ៍គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ និងការលើកលែងទោស និងការអនុគ្រោះទោស), E51/15, ៣ ខែវិច្ឆិកា ឆ្នាំ ២០១១ (ឯកសារសាធារណៈ), កថាខ័ណ្ឌ ៤៣។

[39] សូមមើល លេខយោងទី៤១ ខាងក្រោម។

[40] United Nations, *Vienna Convention on Consular Relations*, 24 April 1963, available at: https://www.refworld.org/docid/3ae6b3648.html [accessed 25 April 2019]

ផ្អែកលើមាត្រា៩៨[41] នេះហើយ សហរដ្ឋអាមេរិក ទោះបីមិនមែនជាភាគី នៃលក្ខន្តិកៈរ៉ូមក្តី រដ្ឋនេះបានចុះកិច្ចព្រមព្រៀងទ្វេភាគីជាមួយរដ្ឋមួយចំនួន ក្នុងនោះមានកម្ពុជា ឡាវ ហ្វីលីពីន ទីម័រខាងកើត សិង្ហបុរី ថៃ ផងដែរ បង្កើតជា កាតព្វកិច្ច ទៅវិញទៅមក (Reciprocal Obligation) មិនបញ្ជូនជនសង្ស័យទៅ "តពអ"។[42]

ជាចុងក្រោយ មានការរិះគន់ថា "តពអ" រើសអើងកាត់ទោសតែមេដឹកនាំនៃប្រទេសក្រីក្រ ជាពិសេសមេដឹកនាំស្បែកខ្មៅ នៃទ្វីបអាហ្វ្រិក។[43] អ្នកនិពន្ធរូបនេះ មិនហ៊ានអះអាងថាខុស ឬត្រូវទេ ក៏ប៉ុន្តែសូមធ្វើការកត់សម្គាល់ខ្លះៗ។ តាមទ្រឹស្តីច្បាប់អន្តរជាតិ កាតព្វកិច្ចក្នុងសន្ធិ-សញ្ញាជាទូទៅចងចំណងដល់រដ្ឋណាដែល ចូលជាភាគី។[44] ការចូលជាភាគីនេះ ដោយស្ម័គ្រចិត្ត គ្មានការបង្ខំ។[45] ប្រទេសមហាអំណាច ប្រទេសអ្នកមាន ពិចារណា និងសម្រេចមិនចូលជាភាគីជាការសម្រេចចិត្ត។ រដ្ឋនៅប្រទេសអាហ្វ្រិក បានសម្រេចចូលជាភាគី ដូចនេះ "តពអ" មានសមត្ថកិច្ចលើរដ្ឋទាំងនោះ។ ជាចុងក្រោយ ស្ថានភាពនៃសិទ្ធិមនុស្ស និងការគ្រប់គ្រងរដ្ឋនៃបណ្តាប្រទេសទាំងនោះ មិនបានត្រឹមត្រូវ ដែលនាំឲ្យមានបណ្តឹងទៅ "តពអ"។

---

[41] ១. តុលាការមិនអាចធ្វើសំណើឲ្យបញ្ជូន ឬ សុំជំនួយ ដែលនឹងទាមទាររដ្ឋត្រូវបានស្នើ (Requested State) អនុវត្តមិនស្របនឹងកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ ទាក់ទងនឹងរដ្ឋ ឬអភ័យឯកសិទ្ធិការទូតរបស់បុគ្គល ឬទ្រព្យសម្បត្តិរបស់រដ្ឋទីបី លុះត្រាតែតុលាការ ទទួលបានកិច្ចសហប្រតិបត្តិការជាដំបូងពីរដ្ឋទីបីនោះ បោះបង់នូវអភ័យឯកសិទ្ធ។ ២. តុលាការមិនអាចធ្វើសំណើឲ្យបញ្ជូន ដែលនឹងទាមទារឲ្យរដ្ឋត្រូវបានស្នើ អនុវត្តផ្ទុយនឹងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀង អន្តរជាតិ ដែលតាមកិច្ចព្រមព្រៀងនោះ ការយល់ព្រមរបស់រដ្ឋបញ្ជូន (Sending State) ត្រូវបានទាមទារ ក្នុងការបញ្ជូន ប្រជាពលរដ្ឋនៃរដ្ឋនោះ ទៅតុលាការ លុះត្រាតែតុលាការទទួលការសហការជាដំបូងពីរដ្ឋបញ្ជូន សម្រាប់ការព្រមព្រៀងបញ្ជូន, *see* the Rome Statute, , *supra* note 3។

[42] ប្រជាពលរដ្ឋនៃភាគីមួយ (ភាគីទី១) ក្នុងដែនដីនៃភាគីមួយទៀត ដោយគ្មានការព្រមព្រៀងជាក់ច្បាស់ពីភាគីទី១ នឹងមិនត្រូវបានបញ្ជូន ឬផ្ទេរតាមមធ្យោបាយណាមួយ ទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ដើម្បីគោលបំណងណាមួយឡើយ..., *see* Agreement between the Royal Government of Cambodia and the Government of the United States of America regarding the Non-Surrender of Persons to the International Criminal Court, available at http://guides.ll.georgetown.edu/c.php?g=363527&p=2456099

[43] Crime of Aggression Activated at the ICC: Does it Matter?, https://www.justsecurity.org/49859/crime-aggression-activated-icc-matter/

[44] *Vienna Convention on the Law of Treaties*, 23 May 1969, United Nations, Treaty Series, vol. 1155, p. 331, available at: https://www.refworld.org/docid/3ae6b3a10.html [accessed 25 April 2019], Article 2(b).

[45] មាត្រា ៥១ និង ៥២, United Nations, *Vienna Convention on the Law of Treaties*, 23 May 196 9, United Nations, Treaty Series, vol. 1155, p. 331, available at: https://www.refworld.org/docid/3ae6b3a 10.html [accessed 12 November 2019]

ដោយសារការមិនទុកចិត្ត រួមផ្សំនិងការបារម្ភ រដ្ឋមួយចំនួនមាន ប្រទេសអាហ្វ្រិកខាងត្បូង ហ្វីលីពីន ក្នុងឆ្នាំ២០១៨ ខែកុម្ភៈ បានប្រកាសដកខ្លួនពី "តពអ"។[46] លោកប្រធានាធិបតី Duterte នៃប្រទេសហ្វីលីពីន មានឈ្មោះក្នុងបណ្ដឹងរួចហើយ ទៅ "តពអ" ពាក់ព័ន្ធការសម្លាប់ក្នុងក្របខ័ណ្ឌនៃបង្ក្រាបអំពើជួញដូរគ្រឿងញៀន។[47] មិនមានបទប្បញ្ញត្តិណាហាមឃាត់ ការដកខ្លួនទេ។[48] ការចូលជាភាគី ឬដកខ្លួនលែងជាភាគី ជាកិច្ចអធិបតេយ្យភាព ដូចនេះ មិនមានឧបសគ្គផ្លូវច្បាប់ទេ។[49] ការចុះជាភាគីប្រទេសខ្លះត្រូវឲ្យមានការផ្ដល់សច្ចាប័នដោយសភា។ វាមិនមានភាពច្បាស់លាស់ តាមវិធានអន្តរជាតិ ដែលថា ការដកខ្លួន ត្រូវមានការយល់ព្រមរបស់សភា។ តាមអ្នកនិពន្ធ វាគួរតែមានការ ឯកភាពឲ្យដកពីសភាផងដែរ។ នេះដើម្បីរក្សាឲ្យបាននូវសមាសភាពរដ្ឋជាភាគីឲ្យបានច្រើន តាមរយៈនូវការមិនងាយអនុញ្ញាត្យរដ្ឋដកខ្លួនស្រួលៗពេក។ ស្ថាប័ន អន្តរជាតិ គ្រាន់តែទទួលនូវការជូនដំណឹងជាផ្លូវការពីហ្វីលីពីន។ វាទំនងជាផ្អែកតាមការអនុវត្តក្នុងស្រុក។ ករណី ហ្វីលីពីន មានបណ្ដឹងទៅតុលាការកំពូល ប្រឆាំងរឿងនេះ។[50] ទោះបីជាយ៉ាងនេះក្ដី ការដកខ្លួន នឹងយឺតពេល ប្រសិនដំណើរការស៊ើបអង្កេតជាផ្លូវការ ដោយ "តពអ" កើតមានរួចហើយ។ នេះករណី Burundi ដែលជារដ្ឋដំបូងដកខ្លួនបន្ទាប់ពីមានការស៊ើបអង្កេតជាផ្លូវការដោយ "តពអ" រួចហើយ។[51]

---

[46] ICC Statement on The Philippines' notice of withdrawal: State participation in Rome Statute system essential to international rule of law, https://www.icc-cpi.int/Pages/item.aspx Name= pr1371

[47] *Id.*,

[48] ១.តាមរយៈការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ រដ្ឋភាគី អាចដកខ្លួនចេញពីលក្ខន្តិកៈនេះ។ ការដកខ្លួន នឹងមានសុពលភាពមួយឆ្នាំបន្ទាប់ពីថ្ងៃជូនដំណឹង លើកលែងការជូនដំណឹងកំណត់រយៈពេលយូរជាងនេះ។ ២. រដ្ឋនឹងមិនត្រូវរួចពីកាតព្វកិច្ច ដោយសារមូលហេតុនៃការដកខ្លួនពីកាតព្វកិច្ច ដែលកើតមានក្នុងអំឡុងពេលខ្លួននៅជាភាគី រាប់បញ្ចូលកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុដែលមាន។ ការដកខ្លួននេះ នឹងមិនប៉ះពាល់ដល់កិច្ចសហការណាមួយជានឹងតុលាការ ពាក់ព័ន្ធនឹងការស៊ើបអង្កេត និងដំណើរការនីតិវិធីទាក់ទង ដែលរដ្ឋភាគីមានកាតព្វកិច្ច សហការចាប់ផ្ដើមមុនថ្ងៃដកខ្លួនបានចូលជាធរមាន និងមិនប៉ះពាល់ដល់ការពិចារណាលើក្ដីក្ដាំ ដែលតុលាការកំពុងពិចារណា មុនថ្ងៃនៃការដកខ្លួនមានសុពលភាព, Article 127 of the Rome Statute

[48] ICC Statement on The Philippines' notice of withdrawal, *supra* note 46

[49] ICC Statement on The Philippines' notice of withdrawal, *supra* note 46.

[50] Philippines Officially Leaves the International Criminal Court, https://www.nytimes. com/ 2019/03/ 17/world/asia/philippines-international-criminal-court.html

[51] Burundi បានតម្កល់ឯកសារផ្ដល់សច្ចាប័នដល់លក្ខន្តិកៈទីក្រុងរ៉ូមក្នុងថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ២០០៤។ រដ្ឋនេះបានដកខ្លួនពីលក្ខន្តិកៈ ហើយមានអានុភាពក្នុងថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០១៧។ តុលាការព្រហ្មទណ្ឌអន្តរជាតិ អនុវត្តយុត្តាធិការរបស់ខ្លួន លើបទឧក្រិដ្ឋ ក្នុងដែនដីរបស់ Burundi ឬប្រព្រឹត្ត ដោយជនជាតិរបស់ខ្លួន ពីថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០០៤ ដល់ ២៦ ខែតុលា ឆ្នាំ ២០១៧, see https://www.icc-cpi.int/burundi 127.

## ៤. សង្ខេប

តុលាការនេះ បានជួបបញ្ហាប្រឈមមួយចំនួនក្តី ក៏ប៉ុន្តែមានចំណុចវិជ្ជមានជាច្រើនផងដែរ។ តុលាការ មានលក្ខណៈអចិន្ត្រៃយ៍ សម្រាប់វិនិច្ឆ័យសេចក្តីអំពើឧក្រិដ្ឋកើតឡើងនៅទូទាំងពិភពលោក។ យន្តការនេះ នឹងនាំឲ្យមានការថមថយនូវអំពើហិង្សា ដែលកំពុងកើតមានឡើងដោយសារការសម្រេចចិត្តស៊ើបអង្កេតលើមេដឹកនាំ ដែលកំពុងចូលរួមក្នុងសង្គ្រាម។

"តពអ" បំពេញបន្ថែម លើតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលមានស្រាប់ ហើយក៏បំពេញបន្ថែម លើយន្តការតុលាការជាតិ កាត់ទោសបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ ពង្រឹងសមត្ថភាពតុលាការជាតិ តាមរយៈការសហការ។ ICC ទើបតែមានដំណើរការ ហើយដែលមានការងារជាច្រើនត្រូវធ្វើ។ អាស្រ័យហេតុនេះ ការវាយតម្លៃលើសមិទ្ធផលជាក់លាក់ណាមួយត្រូវរងចាំពេលវេលា។

# ច្បាប់ធនាគារ

# តួនាទី និងការទទួលខុសត្រូវរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

## (ក្រោមក្របខណ្ឌច្បាប់ពាណិជ្ជកម្ម និងច្បាប់គ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា)

លោក អ៊ុក កុសល*

## ១. សេចក្តីផ្តើម

ធនាគារជាតិនៃកម្ពុជាត្រូវបានបង្កើតឡើងវិញនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំនាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩។[52] រយៈពេលប្រហែលជាងមួយទសវត្សក្រោយមកគឺក្នុងឆ្នាំ១៩៩១ គេឃើញមានវត្តមានធនាគារពាណិជ្ជដំបូងគេនៅក្នុងប្រទេសកម្ពុជា ដែលមានឈ្មោះថា ធនាគារពាណិជ្ជកម្ពុជា (Cambodia Commercial Bank) ដែលត្រូវបានបង្កើតឡើងក្រោមទម្រង់ជាធនាគារវិនិយោគរួមគ្នារបស់រដ្ឋ ដើម្បីទាក់ទាញអ្នកវិនិយោគ និងបម្រើឲ្យសកម្មភាពអាជ្ញាធរអ៊ិនតាក់ប្រចាំនៅកម្ពុជា។[53] ប្រព័ន្ធធនាគារនៅកម្ពុជា មានការរីកចម្រើនគួឲ្យកត់សម្គាល់ ចាប់តាំងពីពាក់កណ្តាលទសវត្សឆ្នាំ១៩៩០ បន្ទាប់ពីមានការដាក់ឲ្យអនុវត្តនូវច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងច្បាប់និងបទប្បញ្ញត្តិនានា ក៏ដូចជាការធ្វើកំណែទម្រង់វិស័យធនាគារក្នុងឆ្នាំ១៩៩៨ និងឆ្នាំ២០០១ ដែលមានជាអាទិ៍ដូចខាងក្រោម[54]៖

ក. ការលុបបំបាត់នូវលក្ខខណ្ឌតម្រូវឲ្យមានភាគហ៊ុនចំនួន ១៥% (ដប់ប្រាំភាគរយ) របស់ធនាគារជាតិនៃកម្ពុជា នៅក្នុងធនាគារឯកជនទាំងអស់។

ខ. ការចាត់ថ្នាក់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុជាបីប្រភេទគឺ ធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ និង

---

* លោក អ៊ុក កុសល គឺជានាយកផ្នែកច្បាប់នៃក្រុមហ៊ុនឯកជនមួយ។ រាល់មតិយោបល់ដែលលើកឡើងនៅក្នុងអត្ថបទនេះ គឺជាទស្សនៈផ្ទាល់ខ្លួនរបស់អ្នកនិពន្ធ ដោយមិនបានឆ្លុះបញ្ចាំង ឬបង្ហាញពីទស្សនៈរបស់ស្ថាប័នដែលអ្នកនិពន្ធធ្វើការឡើយ។

[52] https://www.nbc.org.kh/about_the_bank/history_of_nbc.php, visited on 22 May 2019

[53] Ibid.

[54] Jan Putnis, The Banking Regulation Review, Ninth Edition 2018, p 73

គ. ការបង្កើនដើមទុនចុះបញ្ជីអប្បបរមារបស់ធនាគារពាណិជ្ជពី USD៥.០០០.០០០ (ប្រាំលានដុល្លារអាមេរិក ដល់ USD១២.៥០០.០០០ (ដប់ពីរលានប្រាំរយពាន់ដុល្លារអាមេរិក) ដែលបានធ្វើឲ្យធនាគារមួយចំនួនត្រូវបិទទ្វារ។

ធនាគារជាតិនៃកម្ពុជា ក៏បានធ្វើការបង្កើនដើមទុនចុះបញ្ជីអប្បបរមារបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុជាបន្តបន្ទាប់។ គិតត្រឹមចុងឆ្នាំ២០១៨ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជារួមមាន ធនាគារពាណិជ្ជចំនួន ៤៣ (ធនាគារក្នុងស្រុកចំនួន ១៥ បុត្រសម្ព័ន្ធធនាគារបរទេសចំនួន ១៥ និងសាខាធនាគារបរទេសចំនួន ១៣) ធនាគារឯកទេសចំនួន ១៤ (ធនាគាររដ្ឋចំនួន ១ និងធនាគារឯកជនចំនួន ១៣) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជនចំនួន ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៧៣ គ្រឹះស្ថានឥណទានជនបទចំនួន ២៧៣ ក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុចំនួន ១៥ អ្នកដំណើរការតតិយភាគីចំនួន ៥ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន ១៤ ក្រុមហ៊ុនក្រេឌីតប្យូរ៉ូកម្ពុជាចំនួន ១ ការិយាល័យតំណាងធនាគារបរទេសចំនួន៥ និងអាជីវកម្មប្តូរប្រាក់ចំនួន ២.៧៣៧។[55]

ដើម្បីឆ្លើយតបនឹងភាពរីកចម្រើន និងដើម្បីពង្រឹងអភិបាលកិច្ចនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា ក្នុងនាមជាអាជ្ញាធរទទួលបន្ទុកគ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បានដាក់ឲ្យអនុវត្តប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងប្រកាសស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របសម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ក្នុងគោលបំណងរៀបចំឲ្យមានរចនាសម្ព័ន្ធគណៈគ្រប់គ្រងគ្រប់ជាន់ថ្នាក់ និងកំណត់អំពីគុណវុឌ្ឍិ និងតួនាទីរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផងដែរ។ ចំណែកឯការទទួលខុសត្រូវទាំងផ្នែកវិន័យ និងផ្នែកព្រហ្មទណ្ឌរបស់អភិបាលនៃគ្រឹះស្ថាន មានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានដូចជាច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងច្បាប់ស្តីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាដើម។

បញ្ញត្តិស្តីពីគុណវុឌ្ឍិ តួនាទី និងការទទួលខុសត្រូវរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហរិញ្ញវត្ថុក៏មានចែងនៅក្នុងក្របខណ្ឌច្បាប់ពាណិជ្ជកម្មផងដែរ ដោយហេតុថាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវស្ថិតនៅក្រោមក្របខណ្ឌច្បាប់ពាណិជ្ជកម្មផង និងនៅក្រោមក្របខណ្ឌច្បាប់គ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផង។

[55] របាយការណ៍ប្រចាំឆ្នាំ ២០១៨ របស់ធនាគារជាតិនៃកម្ពុជា ទំព័រ ៤១។

អត្ថបទនេះ ត្រូវបានបែងចែកជាពីរផ្នែក ដោយធ្វើការពិភាក្សាលើនិយមន័យ និងគុណ-វុឌ្ឍិរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (ផ្នែកទី១) និងតួនាទី និងការទទួលខុសត្រូវរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (ផ្នែកទី២) ក្រោមក្របខណ្ឌច្បាប់ពាណិជ្ជកម្ម និងក្របខណ្ឌច្បាប់គ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

## ២. និយមន័យ និងគុណវុឌ្ឍិរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

### ២.១. និយមន័យ

និយមន័យនៃពាក្យ "អភិបាល" មានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិជាច្រើន ដែលបានដាក់ឲ្យអនុវត្តដោយក្រសួង និងស្ថាប័នមានសមត្ថកិច្ចដែលគ្រប់គ្រងវិស័យពាណិជ្ជកម្ម វិស័យធនាគារ និងហិរញ្ញវត្ថុ ក៏ដូចជាវិស័យមូលបត្រ ហើយនិយមន័យទាំងនេះ ត្រូវបានយកមកអនុវត្តក្នុងវិស័យនីមួយៗរៀងៗខ្លួន។

យោងតាមមាត្រា ៨៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ ពាក្យថា "អភិបាល" មានន័យថា សមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមួយ។[56]

ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់និយមន័យដែលមានលក្ខណៈលម្អិតជាងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ពាក្យថា "អភិបាល" សំដៅទៅលើអ្នកគ្រប់គ្រង ឬការគ្រប់គ្រង ឬអង្គភាពមួយដើម្បីអនុវត្តកិច្ចការរបស់នីតិបុគ្គល។[57]

និយមន័យនេះ ត្រូវបានបកស្រាយកាន់តែលម្អិតនៅក្នុងប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨។ យោងតាមប្រការ ២ នៃប្រកាសនេះ ពាក្យថា "អភិបាល" ឬ"ក្រុមប្រឹក្សាភិបាល" មានន័យថា គណៈគ្រប់គ្រងដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យលើការគ្រប់គ្រង និងស្ថានភាពរបស់គ្រឹះស្ថានក្នុងនាមភាគទុនិក។[58]

---

56 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ៨៨។

57 ក្រមរដ្ឋប្បវេណីចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ សន្ទានុក្រម។

58 ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ មាត្រា ២។

## ២.២.គុណវុឌ្ឍិរបស់អភិបាល និងសមាសភាពក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

### ២.២.១.គុណវុឌ្ឍិរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ មិនបានកម្រិត ឬកំណត់គុណវុឌ្ឍិ (ក្រៅពីលក្ខខណ្ឌអាយុ) សម្រាប់បុគ្គលដែលអាចបំពេញតួនាទីជាអភិបាលរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ឬក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតទេ ដោយសារតែច្បាប់នេះ គឺជាច្បាប់គោលដែលគ្រប់គ្រងរាល់ក្រុមហ៊ុនទាំងឡាយដែលធ្វើពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលជាទូទៅ គុណវុឌ្ឍិលម្អិតរបស់អភិបាលមានកំណត់នៅក្នុងច្បាប់ ឬបទប្បញ្ញត្តិដែលគ្រប់គ្រងវិស័យជាក់លាក់នីមួយៗ។ មាត្រា ១២០ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ ចែងថា រូបវន្តបុគ្គលដែលមានសមត្ថភាពមានអាយុលើសពី១៨ឆ្នាំឡើងទៅ អាចបម្រើការងារជាអភិបាលរបស់ក្រុមហ៊ុនបាន។ អភិបាលមិនចាំបាច់ជាម្ចាស់ភាគហ៊ុន ឬមិនចាំបាច់តម្រូវឲ្យមានមានលក្ខណៈសម្បត្តិណាផ្សេងទៀតឡើយ លើកលែងតែ លក្ខន្តិកៈរបស់ក្រុមហ៊ុនតម្រូវឲ្យមានលក្ខណ្ឌផ្សេងពីនេះ។[59]

ផ្ទុយពីក្រុមហ៊ុនដែលប្រកបពាណិជ្ជកម្មទូទៅ លក្ខខណ្ឌតម្រូវដើម្បីអាចបម្រើការងារជាអភិបាលនៅក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានលក្ខណៈតឹងរឹង ដែលអភិបាលត្រូវបានតម្រូវឲ្យមានសមត្ថភាព និងគុណវុឌ្ឍិគ្រប់គ្រាន់។ បន្ថែមពីលើលក្ខខណ្ឌទូទៅដែលមានកំណត់នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អភិបាលដែលអាចបម្រើការងារនៅក្នុងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវមានគុណវុឌ្ឍិ និងឆ្លងកាត់ការត្រួតពិនិត្យយ៉ាងហ្មត់ចត់ដោយអាជ្ញាធរអាណាព្យាបាល (ធនាគារជាតិនៃកម្ពុជា) ដូចខាងក្រោម[60]៖

- ឆ្លងកាត់ដំណើរការលក្ខខណ្ឌវិនិច្ឆ័យដ៏ត្រឹមត្រូវ និងសមស្របដោយធនាគារជាតិនៃកម្ពុជា
- យល់ពីតួនាទីរបស់ខ្លួន រួមទាំងទម្រង់ហានិភ័យរបស់គ្រឹះស្ថាន
- បើចាំបាច់ត្រូវទទួលការបណ្តុះបណ្តាល ដើម្បីរក្សាបានជំនាញរួមគ្នា
- យល់ពីភារកិច្ចរបស់ខ្លួនចំពោះភាគទុនិក ចំពោះគ្រឹះស្ថាន និងចំពោះអ្នកដែលមានប្រយោជន៍ពាក់ព័ន្ធ

[59] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ១២០។

[60] ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ មាត្រា ៣។

- យល់ដឹងពីបរិស្ថានច្បាប់ និងបទប្បញ្ញត្តិទាំងមូល ដើម្បីយល់ច្បាស់អំពីបញ្ហាដែលអាចកើតមានឡើង
- តាមដានស្ថានភាពទីផ្សារបច្ចុប្បន្ន និងយល់ដឹងអំពីបរិស្ថានប្រកួតប្រជែងនៃអាជីវកម្មរបស់គ្រឹះស្ថាន
- មានពេលវេលា និងថាមពលដែលអាចបំពេញការងារប្រកបដោយប្រសិទ្ធភាព។

គុណវុឌ្ឍិរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវបានបកស្រាយកាន់តែលម្អិតថែមទៀត នៅក្នុងប្រកាសស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្របសម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ។ យោងតាមប្រការ ៩ នៃប្រកាសនេះ ដើម្បីអាចកំណត់ថាបុគ្គលណាមួយមានលក្ខខណ្ឌត្រឹមត្រូវ និងសមស្របគ្រប់គ្រាន់សម្រាប់បម្រើការងារជាអភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បុគ្គលនោះត្រូវបានវាយតម្លៃដោយផ្អែកលើគុណវុឌ្ឍិ និងលក្ខខណ្ឌវិនិច្ឆ័យដូចខាងក្រោម[61]៖

ក. ភាពស្មោះត្រង់ ភាពសុចរិត កិត្តិនាម និងភាពត្រឹមត្រូវ

ខ. ការសិក្សា ចំណេះដឹង និងសមត្ថភាព

គ. ស្ថានភាពហិរញ្ញវត្ថុរឹងមាំ។

ដើម្បីវាយតម្លៃពីភាពស្មោះត្រង់ ភាពសុចរិត និងភាពត្រឹមត្រូវរបស់អភិបាល ធនាគារជាតិនៃកម្ពុជា នឹងធ្វើការពិចារណាលើកត្តាសមស្របជាច្រើនដូចជា (i) ការត្រួតពិនិត្យលើលិខិតថ្កោលទោសរបស់អភិបាល ដើម្បីអាចដឹងថាតើបុគ្គលរូបនេះមានធ្លាប់ត្រូវបានផ្តន្ទាទោសពីបទមជ្ឈឹម ឬបទឧក្រិដ្ឋណាមួយដែរឬទេ (ii) តើអភិបាលធ្លាប់មានកំហុសដោយសារការក្លែងឬផ្តល់នូវភស្តុតាងក្លែងបន្លំ (iii) តើអភិបាលត្រូវបានទទួលទណ្ឌកម្មខាងវិន័យ ឬព្យួរការងារដោយអាជ្ញាធរត្រួតពិនិត្យ ឬគ្រឹះស្ថានវិជ្ជាជីវៈ ឬតុលាការជាសាធារណៈ ឬជាឯកជន (iv) តើអភិបាលធ្លាប់ត្រូវបានគេបញ្ឈប់ពីការងារ ឬបង្ខំឲ្យលាលែងពីតំណែងដោយសារតែពាក់ព័ន្ធលើបញ្ហាភាពសុចរិត ឬភាពស្មោះត្រង់ (v) តើអភិបាលធ្លាប់ជាប់ពាក់ព័ន្ធក្នុងសកម្មភាពដូចជាការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងអំពើពុករលួយ និងលក្ខខណ្ឌវិនិច្ឆ័យជាច្រើនទៀត។[62]

[61] ប្រកាសស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប សម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ប្រការ ៩។

[62] ប្រកាសស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប សម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ប្រការ ១០។

ចំណែកឯការវាយតម្លៃលើការសិក្សា ចំណេះដឹង និងសមត្ថភាពរបស់អភិបាលវិញ ធនាគារជាតិនៃកម្ពុជានឹងពិចារណាលើកត្តាពាក់ព័ន្ធដូចជា (i) ប្រវត្តិសិក្សារបស់អភិបាលដោយពិនិត្យមើលលើសញ្ញាបត្រ ឬវិញ្ញាបនបត្រផ្សេងៗ (ii) បទពិសោធន៍របស់អភិបាលក្នុងការបំពេញមុខតំណែងពីមុនមក (iii) ចំណេះដឹងផ្នែកអាជីវកម្ម និងកត្តាផ្សេងៗទៀត។[63] នេះគឺជាលក្ខខណ្ឌវិនិច្ឆ័យគ្រឹះ និងមានសារៈសំខាន់ព្រោះថា ដើម្បីអាចដឹកនាំ គ្រប់គ្រង និងអនុវត្តប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុប្រកដោយប្រសិទ្ធភាព សុវត្ថិភាព និងមានភាពរឹងមាំ អភិបាលដែលជាគណៈគ្រប់គ្រងជាន់ខ្ពស់ត្រូវតែជាបុគ្គលដែលមានការសិក្សា ចំណេះដឹង បទពិសោធន៍ និងសមត្ថភាពគ្រប់គ្រាន់ដើម្បីអាចស្វែងយល់នូវតម្រូវការបច្ចេកទេសអាជីវកម្ម និងហានិភ័យដែលពាក់ព័ន្ធ។

លក្ខខណ្ឌវិនិច្ឆ័យទី៣ ដែលធនាគារជាតិនៃកម្ពុជាធ្វើការពិនិត្យលើគឺ ភាពរឹងមាំផ្នែកហិរញ្ញវត្ថុរបស់អភិបាល ដែលជាទូទៅធនាគារជាតិនៃកម្ពុជា នឹងពិចារណាលើកត្តាពាក់ព័ន្ធដូចជា (i) តើអភិបាលនោះមានសមតុល្យឥណទានហួសកាលកំណត់នៅធនាគារផ្សេង និងមិនទាន់បានជម្រះស្ថានភាពនេះនៅឡើយ (ii) អភិបាលបានធ្វើការសម្រុះសម្រួល ជាមួយម្ចាស់បំណុល ឬបានដាក់ពាក្យសុំក្ស័យធន និងកត្តាពាក់ព័ន្ធផ្សេងៗទៀត។[64]

បុគ្គលដែលគ្មានគុណវុឌ្ឍិ និងមិនបានបំពេញតាមលក្ខខណ្ឌដូចបានរៀបរាប់ខាងលើ មិនអាចត្រូវបានតែងតាំងជាអភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទេ ព្រោះថារាល់ការតែងតាំងអភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវឆ្លងកាត់ការវាយតម្លៃយ៉ាងហ្មត់ចត់ (លើគុណវុឌ្ឍិ និងលក្ខខណ្ឌវិនិច្ឆ័យ) ដោយធនាគារជាតិនៃកម្ពុជា។ បន្ថែមពីលើនេះទៅទៀត រាល់ការតែងតាំងអភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអាចធ្វើទៅបាន លុះត្រាតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីធនាគារជាតិនៃកម្ពុជា។[65]

[63] ប្រកាសស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប សម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ប្រការ ១១។

[64] ប្រកាសស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប សម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ប្រការ ១២។

[65] ប្រកាសស្តីពីលក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវ និងសមស្រប សម្រាប់បុគ្គលដាក់ពាក្យស្នើសុំ និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ប្រការ ១៥។

## ២.២.២.សមាសភាពក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ បានកំណត់ចំនួនអប្បបរមានៃអភិបាលរបស់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ យោងតាមប្រការ ១១៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវមានអភិបាលម្នាក់ ឬច្រើននាក់។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតត្រូវមានអភិបាលយ៉ាងតិចបីនាក់។[66]

ច្បាប់ និងបទប្បញ្ញត្តិគ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមិនបានកំណត់ចំនួនអប្បរមានៃអភិបាលរបស់គ្រឹះស្ថានធនាគារពាណិជ្ជទេ ក៏ប៉ុន្តែបានកំណត់ចំនួនអប្បបរមានៃអភិបាលសម្រាប់ធនាគារឯកទេស និងគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ។ ទោះបីជាយ៉ាងណាក៏ដោយ ចំនួនអប្បបរមានៃអភិបាលសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវបានកំណត់ដោយច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ ដោយសារតែគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវតែបង្កើតឡើងក្រោមទម្រង់ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ មាត្រា ៨៥ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ ចែងថា ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតមិនអាចបង្កើតឡើងក្រោមច្បាប់នេះក្នុងគោលបំណងធ្វើអាជីវកម្មធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនឥណទានឡើយ។[67] ដូច្នេះ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវតែបង្កើតឡើងក្រោមទម្រង់ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត និងត្រូវមានអភិបាលយ៉ាងតិចចំនួនបីរូប។

ទាំងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ និងច្បាប់និងបទប្បញ្ញត្តិគ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមិនបានកំណត់ចំនួនអតិបរមានៃអភិបាលសម្រាប់ក្រុមហ៊ុន ឬគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទេ។ ដូច្នេះ ក្រុមហ៊ុន ឬគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអាចកំណត់ចំនួនអតិបរមានៃអភិបាលនៅក្នុងលក្ខន្តិកៈរបស់ខ្លួន អាស្រ័យទៅតាមទំហំ និងតម្រូវការអាជីវកម្មជាក់ស្តែង។

លក្ខណៈពិសេសរបស់ច្បាប់ និងបទប្បញ្ញត្តិគ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុគឺលក្ខខណ្ឌតម្រូវឲ្យបញ្ចូលអភិបាលឯករាជ្យចូលទៅក្នុងសមាសភាពក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ សម្រាប់ធនាគារពាណិជ្ជ ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិក

[66] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ១១៨។

[67] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ៨៥។

ឯករាជ្យយ៉ាងតិចពីររូប។ សម្រាប់ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិកយ៉ាងតិចបីរូប ដែលក្នុងនោះ មួយរូបត្រូវតែជាសមាជិកឯករាជ្យ។ ប្រសិនបើគ្រឹះស្ថានមានសមាជិកលើសពី៣រូប គ្រឹះស្ថានត្រូវធានាថាយ៉ាងតិចមួយភាគបី នៃសមាជិកត្រូវតែជាសមាជិកឯករាជ្យ។[68] ពាក្យថា អភិបាលឯករាជ្យ សំដៅលើអភិបាលដែលមានសមត្ថភាពវិនិច្ឆ័យដោយឯករាជ្យលើទស្សនៈនៃការគ្រប់គ្រងផលប្រយោជន៍នយោបាយ ឬផលប្រយោជន៍ខាងក្រៅដែលមិនសមស្រប។[69] និយមន័យខាងលើនេះ មានលក្ខណៈទូលាយ ដែលអាចនាំឲ្យមានការបកស្រាយខុសៗគ្នា។ ផ្អែកតាមការបកស្រាយនាពេលបច្ចុប្បន្ន អភិបាលមិនឯករាជ្យសំដៅលើបុគ្គលដែលមានមុខតំណែង និងបម្រើការងារនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនរួមទាំងក្រុមហ៊ុនបុត្រសម្ព័ន្ធនៅបរទេសផងដែរ ដែលមានន័យថាបុគ្គលិករបស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធមិនអាចធ្វើជាអភិបាលឯករាជ្យរបស់គ្រឹះស្ថានធនាគារពាក់ព័ន្ធនៅកម្ពុជាបានទេ។ ក៏ប៉ុន្តែ អភិបាលឯករាជ្យនៃក្រុមហ៊ុនមេ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធនៅបរទេស ត្រូវបានអនុញ្ញាតឲ្យធ្វើជាអភិបាលឯករាជ្យនៅក្នុងធនាគារពាក់ព័ន្ធនៅកម្ពុជា។[70] ផ្អែកតាមនិយមន័យ និងការបកស្រាយខាងលើ បុគ្គលិកដែលកាន់មុខតំណែងដែលឯករាជ្យពីប្រតិបត្តិការអាជីវកម្ម (ឧទាហរណ៍ ផ្នែកសវនកម្ម ឬផ្នែកប្រតិបត្តិតាម) នៅក្នុងក្រុមហ៊ុនមេ ឬក្រុមហ៊ុនបុត្រសម្ព័ន្ធនៅបរទេសគួរតែអាចបំពេញតួនាទីជាអភិបាលឯករាជ្យនៅក្នុងធនាគារពាក់ព័ន្ធនៅកម្ពុជាផងដែរ។

## ៣. តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

### ៣.១ តួនាទី និងភារកិច្ចរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

សម្រាប់ក្រុមហ៊ុនពាណិជ្ជកម្មទូទៅ ការចាត់ចែងសកម្មភាពអាជីវកម្ម និងការងារប្រតិបត្តិការរបស់ក្រុមហ៊ុនត្រូវបានប្រគល់ជូនក្រុមប្រឹក្សាភិបាល។ សិទ្ធិ និងតួនាទីទូទៅរបស់អភិបាលអាចត្រូវបានកំណត់នៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន។

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ បានកំណត់សិទ្ធិ និងតួនាទីជាទូទៅរបស់អភិបាលរបស់ក្រុមហ៊ុនពាក់ព័ន្ធនឹងការគ្រប់គ្រងក្រុមហ៊ុន។ យោងតាមមាត្រា ១១៩ នៃ

---

[68] ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ប្រការ ៦។

[69] ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ប្រការ ៦ កថាខណ្ឌ ១។

[70] Jan Putnis, The Banking Regulation Review, Ninth Edition 2018, p 77

ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ លក្ខន្តិកៈរបស់ក្រុមហ៊ុនត្រូវចែងពីសិទ្ធិរបស់អភិបាលដែលមានជាអាទិ៍ដូចជា[71]៖

ក. តែងតាំង និងដកហូតសិទ្ធិអ្នកគ្រប់គ្រងទាំងអស់ និងកំណត់នូវសិទ្ធិច្បាស់លាស់សម្រាប់អ្នកគ្រប់គ្រងទាំងនោះ។

ខ. កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗដល់អ្នកគ្រប់គ្រងទាំងនោះ។

គ. កំណត់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗសម្រាប់អភិបាលទាំងអស់ ហើយដាក់ជូនទៅម្ចាស់ភាគហ៊ុនដើម្បីសុំសេចក្តីសម្រេច។

ឃ. ចេញប័ណ្ណកំណត់សន្យា សញ្ញាប័ណ្ណ និងលិខិតស្នាម ដែលបញ្ជាក់ថាមានបំណុល និងតឹកតាង ផ្សេងៗនៃបំណុលរបស់ក្រុមហ៊ុន និងកំណត់នូវលក្ខណៈដាច់ខាត និងលក្ខណៈធៀបរបស់លិខិតស្នាមទាំងឡាយនេះ។

ង. ស្នើសុំម្ចាស់ហ៊ុន ដើម្បីធ្វើការកែប្រែលក្ខន្តិកៈ ឬលុបចោលលក្ខន្តិកៈរបស់ក្រុមហ៊ុន។

ច. ស្នើសុំម្ចាស់ហ៊ុន នូវកិច្ចសន្យារំលាយចូលគ្នា ឬរួមបញ្ចូលគ្នារវាងក្រុមហ៊ុន និងបុគ្គលផ្សេងណាមួយ។

ឆ. ស្នើសុំម្ចាស់ហ៊ុន ដើម្បីលក់ទ្រព្យសម្បត្តិក្រុមហ៊ុនទាំងអស់ ឬមួយភាគ។

ជ. ស្នើសុំម្ចាស់ហ៊ុន ដើម្បីរំលាយ ឬជម្រះបញ្ជីក្រុមហ៊ុន។

ឈ. ប្រកាសភាគលាភនៅតាមគោលការណ៍គណនេយ្យ និងតាមលក្ខណ្ឌនៃការដាក់ភាគហ៊ុន ប្រភេទនីមួយៗដែលមានសិទ្ធិទទួលបានភាគលាភ។

ញ. ចេញប័ណ្ណភាគហ៊ុនរបស់ក្រុមហ៊ុនទៅតាមវិសាលភាព ដែលបានចែងនៅក្នុងលក្ខន្តិកៈនៃក្រុមហ៊ុន។

ដ. ខ្ចីប្រាក់។

ឋ. បោះចេញ បោះចេញជាថ្មី ឬលក់មូលប័ត្ររបស់ក្រុមហ៊ុន។

ឌ. ចុះកិច្ចសន្យាក្នុងនាមក្រុមហ៊ុន។

ឍ. ធ្វើហ៊ីប៉ូតែក ចុះកិច្ចសន្យាបញ្ចាំ បើមិនដូច្នេះទេបង្កើតផលប្រយោជន៍ពីមូលបត្រចំពោះទ្រព្យសម្បត្តិទាំងអស់ ឬទ្រព្យសម្បត្តិណាមួយរបស់ក្រុមហ៊ុនដើម្បីធ្វើការធានាកាតព្វកិច្ចណាមួយរបស់ក្រុមហ៊ុន។

---

[71] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ១១៩។

ណ. រៀបចំការបិទបញ្ជីគណនេយ្យនៃកាលបរិច្ឆេទនីមួយៗ ជូនម្ចាស់ហ៊ុន និងស្នើចាត់ចែងលទ្ធផលប្រចាំឆ្នាំជូនមហាសន្និបាតនៃម្ចាស់ហ៊ុន។

ផ្អែកតាមមាត្រា ១១៩ ខាងលើ អភិបាល ឬក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមានសិទ្ធិ និងតួនាទីយ៉ាងទូលំទូលាយក្នុងការគ្រប់គ្រង និងចាត់ចែងសកម្មភាពអាជីវកម្ម និងប្រតិបត្តិការរបស់ក្រុមហ៊ុន លើកលែងតែកិច្ចការ ឬសកម្មភាពសំខាន់ៗមួយចំនួនរបស់ក្រុមហ៊ុន ដែលមិនមែនជាប្រតិបត្តិការជាធម្មតារបស់ក្រុមហ៊ុន (មានជាអាចំដូចជា ការកែប្រែលក្ខន្តិកៈ ឬការលុបចោលលក្ខន្តិកៈក្រុមហ៊ុន និងការលក់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន) ត្រូវស្នើសុំការសម្រេចពីម្ចាស់ហ៊ុន។

ក្រៅពីសិទ្ធិ និងតួនាទីដែលមានចែងនៅក្នុងលកន្តិកៈ សិទ្ធិ និងតួនាទីលម្អិតរបស់អភិបាលអាចមានចែងនៅក្នុងខចែង និងលក្ខខណ្ឌយោងរបស់ក្រុមប្រឹក្សាភិបាល ឬកិច្ចសន្យារបស់ម្ចាស់ហ៊ុន។ ប៉ុន្តែសិទ្ធិនិងតួនាទីរបស់អភិបាលដែលមានចែងក្នុងលក្ខន្តិកៈត្រូវមានសុពលភាពអនុវត្ត ក្នុងករណីដែលមានភាពមិនស្របគ្នារវាងសិទ្ធិ និងតួនាទីរបស់អភិបាលដែលមានចែងនៅក្នុងឯកសារដូចបានរៀបរាប់ខាងលើ ព្រោះថា លក្ខន្តិកៈរបស់ក្រុមហ៊ុនជាវិធានគោលសម្រាប់គ្រប់គ្រងក្រុមហ៊ុន និងត្រូវបានចុះបញ្ជី និងទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ស្រដៀងគ្នានឹងក្រុមហ៊ុនពាណិជ្ជកម្មទូទៅ អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក៏ត្រូវទទួលបានសិទ្ធិ និងតួនាទី ដែលមានចែងក្រោមមាត្រា ១១៩ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ ផងដែរ។ ប៉ុន្តែ បន្ថែមពីលើនេះ ដើម្បីលើកកម្ពស់អភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានកំណត់សិទ្ធិនិងតួនាទីជាក់លាក់មួយចំនួន ដែលមានលក្ខណៈតឹងរឹង និងលម្អិតជាងសិទ្ធិនិងតួនាទីដែលមានចែងក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ សម្រាប់អភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ យោងតាមប្រការ ៤ នៃប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ សមាជិកក្រុមប្រឹក្សាភិបាលត្រូវសកម្មការងារ និងត្រូវមានសិទ្ធិ និងតួនាទីដូចខាងក្រោម[72]៖

ក. អនុម័តយុទ្ធសាស្ត្រ គោលនយោបាយហានិភ័យ និងនីតិវិធីគ្រប់គ្រងហានិភ័យទាំងនោះ។

ខ. រៀបចំរចនាសម្ព័ន្ធរបស់ខ្លួន ដើម្បីឲ្យការពិភាក្សាមានប្រសិទ្ធភាព។

[72] ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ប្រការ ៤។

គ. ជ្រើសរើស ត្រួតពិនិត្យ ផ្លាស់ប្តូរនាយកប្រតិបត្តិសំខាន់ៗ។
ឃ. សាកសួរអ្នកគ្រប់គ្រងជាន់ខ្ពស់។
ង. រៀបចំប្រព័ន្ធរាយការណ៍មួយ ដែលអាចជួយឲ្យការអនុវត្តកាតព្វកិច្ចរបស់សមាជិកក្រុមប្រឹក្សាភិបាល ដែលមានលក្ខណៈយល់ដឹងបាន និងទាន់ពេល។
ច. ជួបជាមួយអ្នកគ្រប់គ្រងជាន់ខ្ពស់ និងសវនករផ្ទៃក្នុងឲ្យបានទៀងទាត់
ឆ. វាយតម្លៃការប្រតិបត្តិរបស់អ្នកគ្រប់គ្រងជាន់ខ្ពស់ឲ្យបានទៀងទាត់
ជ. វាយតម្លៃគោលនយោបាយរបស់គ្រឹះស្ថានឲ្យបានទៀងទាត់លើការអនុវត្ត និងបញ្ហាជាសក្តានុពលដែលអាចសម្គាល់បាន។
ឈ. អនុវត្តនូវការវិនិច្ឆ័យសម្រាប់អនាគត ដើម្បីសម្គាល់នូវបញ្ហាជាសក្តានុពលដែលគ្រឹះស្ថានត្រូវប្រឈម និងធានាថាសកម្មភាពកែតម្រូវសមស្របត្រូវបានអនុវត្តជាបន្ទាន់ ប្រសិនបើចាំបាច់។

ផ្អែកតាមការរៀបរាប់ខាងលើ អភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានតួនាទីអនុវត្តការងារឲ្យបានត្រឹមត្រូវនិងយ៉ាងសកម្ម ដោយផ្តោតលើការពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងហានិភ័យ (បន្ថែមពីលើការស្វែងរកប្រាក់ចំណេញ) ដើម្បីការពារផលប្រយោជន៍របស់អតិថិជន និងធានានិរន្តរភាពរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

## ៣.២. ការទទួលខុសត្រូវរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

ដូចដែលបានលើកឡើងខាងលើ ការទទួលខុសត្រូវរបស់អភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ មានចែងនៅក្នុងក្របខណ្ឌច្បាប់ពាណិជ្ជកម្ម និងក្របខណ្ឌច្បាប់គ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដោយហេតុថាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវស្ថិតនៅក្រោមក្របខណ្ឌច្បាប់ពាណិជ្ជកម្មផង និងនៅក្រោមក្របខណ្ឌច្បាប់គ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុផង។

### ៣.២.១. ការទទួលខុសត្រូវរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្រោមក្របខណ្ឌច្បាប់ពាណិជ្ជកម្ម

ក្រោមក្របខណ្ឌច្បាប់ពាណិជ្ជកម្មដែលគ្រប់គ្រងសកម្មភាពរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ការខកខានមិនបានបំពេញតួនាទី និងកាតព្វកិច្ចដែលមានចែងនៅក្នុង

ច្បាប់ និងបទប្បញ្ញត្តិជាធរមាន អភិបាលអាចទទួលរងទណ្ឌកម្មផ្នែកវិន័យ (ពិន័យផ្នែករដ្ឋបាល) និងទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ (ពិន័យជាប្រាក់ និងទោសជាប់ពន្ធនាគារ)។

អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវបំពេញតួនាទី និងអនុវត្តសិទ្ធិរបស់ខ្លួនដូចដែលបានរៀបរាប់ខាងលើ ពាក់ព័ន្ធនឹងការចាត់ចែងសកម្មភាពអាជីវកម្មរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដោយធ្វើសកម្មភាពស្មោះត្រង់ក្នុងបំណងល្អ ដើម្បីឲ្យមានផលប្រយោជន៍ខ្ពស់ដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ អភិបាលត្រូវអនុវត្តតួនាទីរបស់ខ្លួនដោយយកចិត្តទុកដាក់ ព្យាយាម និងប្រើប្រាស់ជំនាញដូចបុគ្គលដែលមានមធ្យ័ត អនុវត្តក្នុងកាលៈទេសៈមួយដូចគ្នា (យោងតាមមាត្រា ២៨៩ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥)។[73] យោងតាមមាត្រា ១៣៣ និងមាត្រា ២៩១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ ការអនុវត្តសិទ្ធិ ឬការបំពេញតួនាទីផ្ទុយពីបញ្ញត្តិនៃមាត្រា ២៨៩ ខាងលើ អាចបណ្តាលឲ្យអភិបាលទទួលខុសត្រូវដោយផ្ទាល់ ដោយទទួលរងការពិន័យជាប្រាក់ ឬអាចត្រូវបានចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ ប្រសិនបើទង្វើនោះជាបទល្មើសព្រហ្មទណ្ឌ។ មាត្រា ១៣៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មចែងថា ក្រុមហ៊ុនអាចចេញសងការចំណាយដល់អភិបាលបច្ចុប្បន្ន ឬអភិបាលពីមុន ដែលការចំណាយនោះកើតមានឡើងពីការបំពេញភារកិច្ចដែលបានអនុវត្តដោយស្មោះត្រង់ និងសមហេតុសមផល។[74] តាមអត្ថន័យនៃមាត្រា ១៣៣ នេះ ប្រសិនបើអភិបាលមិនបានបំពេញតួនាទីដោយស្មោះត្រង់ ឬបំពេញតួនាទីដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនបម្រើឲ្យប្រយោជន៍របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលខ្លួនបម្រើការងារទេ អភិបាលរូបនោះនឹងត្រូវទទួលខុសត្រូវដោយខ្លួនឯងផ្ទាល់ ហើយគ្រឹះស្ថាននឹងមិនទូទាត់សងសំណងចំពោះ ការទាមទារ បណ្តឹង ការចំណាយ ឬការខូចខាតនានាដែលកើតមានលើអភិបាល បណ្តាលមកពីទង្វើរបស់ខ្លួនឡើយ។ បន្ថែមពីលើនេះទៀត យោងតាមមាត្រា ២៩១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ប្រសិនបើអភិបាលជាអ្នកប្រគល់សិទ្ធិឲ្យបុគ្គលិក ឬបុគ្គលណាមួយឲ្យប្រព្រឹត្តបទល្មើស ឬអនុញ្ញាត ឬបានយល់ព្រមឲ្យប្រព្រឹត្តបទល្មើស អភិបាលរូបនោះក៏ត្រូវទទួលខុសត្រូវលើបទល្មើសនោះ និងទទួលទោសដូចមានចែងនៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥។[75] ទោសនៃបទល្មើសដែលអភិបាលត្រូវទទួលរងក្រោមមាត្រា ២៩១ នេះ នឹងត្រូវកំណត់ទៅតាមបទល្មើសនីមួយៗដែលបានប្រព្រឹត្ត។

73 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ២៨៩។

74 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ១៣៣។

75 ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ២៩១។

ការខកខានមិនបានប្រកាសពីទំនាស់ផលប្រយោជន៍ស្របតាមប្រការ ១៣៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ ក៏អាចត្រូវបានបកស្រាយថា អភិបាលមិនបានបំពេញតួនាទីដោយស្មោះត្រង់ ឬដើម្បីផលប្រយោជន៍ខ្ពស់បំផុតសម្រាប់គ្រឹះស្ថានទេ ដែលអភិបាលត្រូវទទួលខុសត្រូវទាំងស្រុងលើទង្វើដែលខ្លួនបានប្រព្រឹត្ត ក្នុងករណីដែលក្រុមហ៊ុនទទួលរងការខូចខាតណាមួយ បណ្តាលមកពីការខកខានមិនបានប្រកាសនោះ។

ទោះបីជាច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ បានប្រគល់សិទ្ធិ និងតួនាទីយ៉ាងទូលំទូលាយដល់អភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដូចដែលបានរៀបរាប់ខាងលើក៏ដោយ ក៏ច្បាប់នេះបានកម្រិតសិទ្ធិ និងតួនាទីមួយចំនួនរបស់អភិបាលផងដែរ ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់ហ៊ុន។

ជាក់ស្តែង យោងតាមមាត្រា ១៤០ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ អភិបាលដែលបោះឆ្នោតឲ្យ ឬយល់ព្រមក្នុងការធ្វើសេចក្តីសម្រេចលើការអនុញ្ញាតឲ្យចេញប័ណ្ណភាគហ៊ុនសម្រាប់តម្លៃសមមូល ដែលមិនមែនជាសាច់ប្រាក់ទេ ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នាចំពោះក្រុមហ៊ុន ទៅតាមចំនួនតម្លៃសមមូលដែលបានទទួល ដែលតិចជាងតម្លៃត្រឹមត្រូវជាសាច់ប្រាក់ ដែលក្រុមហ៊ុនបានទទួល ប្រសិនបើប័ណ្ណភាគហ៊ុនដែលបានបោះចេញនោះ សម្រាប់យកទៅលក់យកជាប្រាក់នៅកាលបរិច្ឆេទនៃសេចក្តីសម្រេច។[76] ដូចដែលបានបកស្រាយខាងលើ ប្រសិនបើអភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានបំពេញតួនាទីដោយស្មោះត្រង់ ពុំមានចេតនាទុច្ចរិត និងដើម្បីប្រយោជន៍ខ្ពស់បំផុតរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលខ្លួនបម្រើការងារ អភិបាលរូបនោះនឹងមិនទទួលខុសត្រូវចំពោះការខូចខាតដែលកើតមានឡើងទេ។ ទង្វើបែបនេះត្រូវបានការពារដោយមាត្រា ១៣៣ ខាងលើ និងមាត្រា ១៤០ កថាខណ្ឌ ២ ដែលចែងថា អភិបាលមិនត្រូវទទួលខុសត្រូវទេ ប្រសិនបើអភិបាលនោះបង្ហាញថា មិនបានដឹងថាភាគហ៊ុនដែលបានបោះចេញសម្រាប់តម្លៃសមមូលដែលតិចជាងសាច់ប្រាក់ ដែលគ្រឹះស្ថានអាចនឹងទទួលបាន ប្រសិនបើបណ្ណភាគហ៊ុននោះត្រូវបានបោះផ្សាយសម្រាប់លក់ជាសាច់ប្រាក់។

បញ្ញត្តិនៃមាត្រា ១៤០ ខាងលើនេះ មានសារៈសំខាន់ណាស់ក្នុងការធានាឲ្យមានការអនុវត្តសិទ្ធិ និងកាតព្វកិច្ចក្នុងការកំណត់តម្លៃប័ណ្ណភាគហ៊ុន និងតម្លៃមូលប័ត្រដែលបានផ្តល់ជូនអភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្រោមមាត្រា ១៤៦ នៃច្បាប់ស្តីពីសហគ្រាស

[76] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ១៤០ កថាខណ្ឌ ១។

ពាណិជ្ជកម្មឆ្នាំ ២០០៥ ។ យោងតាមមាត្រា ១៤៦ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ អភិបាលមានសិទ្ធិកំណត់តម្លៃនៃប័ណ្ណភាគហ៊ុន ហើយម្ចាស់ភាគហ៊ុនដែលជាវប័ណ្ណភាគហ៊ុនអាចធ្វើការទូទាត់ជាសាច់ប្រាក់ ជាវត្ថុ ឬជាសេវាពីមុន។[77] ក្នុងករណីនេះ ដើម្បីអាចការពារខ្លួនឲ្យរួចផុតពីការទទួលខុសត្រូវដូចដែលមានចែងក្នុងមាត្រា ១៤០ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម អភិបាលត្រូវធ្វើការវាយតម្លៃដោយប្រុងប្រយ័ត្ន និងកំណត់តម្លៃរបស់វត្ថុ ឬសេវាពីមុន ដែលត្រូវបានប្រើប្រាស់សម្រាប់ទូទាត់ថ្លៃប័ណ្ណភាគហ៊ុនឲ្យបានត្រឹមត្រូវ។ បន្ថែមពីលើនេះទៅទៀត ការទូទាត់ជាសេវាក្នុងពេលអនាគត (ឧ. សេវាគ្រប់គ្រង និងដឹកនាំក្រុមហ៊ុន) ក្រោយពេលដែលប័ណ្ណភាគហ៊ុនត្រូវបានបោះចេញ ហាក់ដូចជាមិនត្រូវបានអនុញ្ញាតឡើយ ព្រោះថាផ្អែកតាមបញ្ញត្តិនៃមាត្រា ១៤៦ នេះ ភាគហ៊ុនមិនត្រូវបានបោះចេញទេ រហូតដល់ការបង់ថ្លៃសម្រាប់ភាគហ៊ុនត្រូវបានធ្វើឡើងគ្រប់ចំនួន។

បន្ថែមពីលើនេះទៀត យោងតាមមាត្រា ១៤១ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ អភិបាលដែលបានបោះឆ្នោត ឬយល់ព្រមចំពោះសេចក្តីសម្រេចដែលអនុញ្ញាតឲ្យមានការទិញមកវិញ នូវភាគហ៊ុនរបស់ ក្រុមហ៊ុនដែលបានលក់កន្លងមក ឬធ្វើការបន្ថយដើមទុនតាមវិធីណាមួយ ឬធ្វើការបែងចែកភាគលាភ ដែលផ្ទុយពីបទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ ត្រូវទទួលខុសត្រូវរួមគ្នា និងដាច់ដោយឡែកពីគ្នានូវរាល់ចំនួនដែលបែងចែក ឬបានបង់ហើយ ដើម្បីស្តារក្រុមហ៊ុនឡើងវិញ។[78] ផ្អែកតាមមាត្រានេះ ប្រសិនបើមានការខាតបង់ណាមួយចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ កើតមានឡើងបណ្តាលមកពីករណីដូចបានរៀបរាប់ខាងលើ អភិបាលដែលបានចូលរួមសម្រេច ត្រូវទទួលខុសត្រូវទូទាត់សំណងជូនគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនោះ ដើម្បីស្តារស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានឡើងវិញ។ សកម្មភាពដែលបានប្រព្រឹត្តដោយអភិបាលក្នុងករណីនេះ មិនអាចត្រូវបានការពារដោយមាត្រា ១៣៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ ទេ ទោះបីជាអភិបាលបានបំពេញភារកិច្ចដោយស្មោះត្រង់ និងដើម្បីប្រយោជន៍ខ្ពស់បំផុតរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលខ្លួនបម្រើការងារក៏ដោយ ព្រោះថានេះជាសកម្មភាពដែលបានប្រព្រឹត្តផ្ទុយពីច្បាប់ និងបទប្បញ្ញត្តិជា ធរមាន។

ដើម្បីអាចរួចផុតពីការទទួលខុសត្រូវក្នុងករណីខាងលើនេះ អភិបាលមិនត្រូវចូលរួមបោះឆ្នោត ឬយល់ព្រមអនុញ្ញាតឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុធ្វើសកម្មភាពណាមួយដូច

[77] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ១៤៦។

[78] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ១៤១។

បានរៀបរាប់ខាងលើ ដែលផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥ ឡើយ។ ដើម្បីអាចបញ្ជាក់ថា អភិបាលណាមួយមិនបានចូលរួមក្នុងសកម្មភាពបែបនេះទេ អភិបាលរូបនោះត្រូវធ្វើការជំទាស់ ឬផ្ញើគំនិតជំទាស់របស់ខ្លួនលើសកម្មភាពនោះ ទៅលេខាធិការរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ស្របតាមនីតិវិធីដែលមានចែងក្នុងមាត្រា ១៤២ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ ២០០៥។[79] ប្រសិនបើមិនដូច្នោះទេ អភិបាលដែលបានចូលរួមនៅក្នុងអង្គប្រជុំ ត្រូវចាត់ទុកថាបានយល់ព្រមនូវរាល់សេចក្តីសម្រេចដែលបានអនុម័ត ឬសកម្មភាពដែលបានធ្វើឡើងនៅក្នុងអង្គប្រជុំ។

ក្រៅពីនេះ អភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក៏មានទំនួលខុសត្រូវក្នុងការធានាថា ប្រតិវេទន៍ប្រចាំឆ្នាំរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលខ្លួនបម្រើការងារ ត្រូវបានតម្កល់ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ យោងតាមប្រការ ១ នៃប្រកាសស្តីពីការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម រាល់ក្រុមហ៊ុនទាំងអស់ដែលបានចុះបញ្ជីពាណិជ្ជកម្ម នៅក្រសួងពាណិជ្ជកម្ម មានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងនឹងស្ថានភាពក្រុមហ៊ុន។[80] ចំណែកឯប្រការ ២ នៃប្រកាសនេះក៏មានចែងថា អ្នកគ្រប់គ្រងក្រុមហ៊ុនត្រូវពិនិត្យ និងផ្ទៀងផ្ទាត់លើភាពត្រឹមត្រូវ នៃបច្ចុប្បន្នភាពព័ត៌មានចុះបញ្ជីពាណិជ្ជកម្ម បំពេញព័ត៌មាន និងភ្ជាប់ឯកសារយោងផ្សេងៗ តាមទម្រង់ដែលមានស្រាប់នៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម។[81]

ផ្អែកតាមបញ្ញត្តិនៃប្រការ ១ និងប្រការ ២ ខាងលើនេះ ការតម្កល់ និងការពិនិត្យលើភាពត្រឹមត្រូវរបស់ប្រតិវេទន៍ប្រចាំឆ្នាំដែលទាក់ទងនឹងស្ថានភាពរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ អាចត្រូវបានបកស្រាយថាជាកាតព្វកិច្ច និងការទទួលខុសត្រូវរបស់អភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនោះ ព្រោះថាអភិបាលគឺជាអ្នកគ្រប់គ្រងរបស់គ្រឹះស្ថាន។ ក្នុងករណីដែលអភិបាលមានការយឺតយ៉ាវមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំឲ្យបានទាន់ពេលវេលាកំណត់ទេ នោះគ្រឹះស្ថាននឹងត្រូវទទួលរងការផាកពិន័យជាទឹកប្រាក់ចំនួន ១.០០០.០០០ រៀល។ លើសពីលើនេះទៅទៀត ក្នុងករណីដែលអភិបាលខកខានមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំចាប់ពីមួយ១ឆ្នាំឡើងទៅ នោះគ្រឹះស្ថានត្រូវបង់ប្រាក់ពិន័យ ព្រមទាំងកម្រៃសេវាប្រតិវេទន៍ប្រចាំឆ្នាំ

[79] ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ១៤២។

[80] ប្រកាសស្តីពីការតម្កល់ប្រតិវេទន៍តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧ ប្រការ ១។

[81] ប្រកាសស្តីពីការតម្កល់ប្រតិវេទន៍តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧ ប្រការ ២។

ទៅតាមចំនួនឆ្នាំដែលខកខាន។[82] ប្រាក់ផាកពិន័យក្រោមមាត្រានេះ អាចក្លាយជាបន្ទុក ឬការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់អភិបាល ព្រោះថាអភិបាលមិនបានអនុវត្តតួនាទីរបស់ខ្លួន ដោយប្រុងប្រយ័ត្នស្របតាមមាត្រា ២៨៩ នៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ ដែលបានបណ្ដាលឲ្យគ្រឹះស្ថានទទួលរងការខាតបង់។

បន្ថែមពីលើកាតព្វកិច្ចក្នុងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ អភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក៏មានតួនាទីពិនិត្យ និងធានាពីភាពត្រឹមត្រូវនៃរបាយការណ៍ និងឯកសារផ្សេងៗ ដែលត្រូវបញ្ជូនទៅម្ចាស់ភាគហ៊ុន និងក្រសួងពាណិជ្ជកម្ម ស្របតាមបញ្ញត្តិនៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម។ ការធ្វើរបាយការណ៍ ឬឯកសារក្លែងក្លាយ ឬការខកខានមិនបានបញ្ជូនរបាយការ ឬឯកសារទៅម្ចាស់ភាគហ៊ុន ត្រូវទទួលរងទោសពិន័យជាប្រាក់ និងជាពន្ធនាគារដូចដែលមានចែងក្នុងមាត្រា២៩០ (ការក្លែងរបាយការណ៍ ឬឯកសារត្រូវទទួលទោសពិន័យជាប្រាក់រហូតដល់ ១០.០០០.០០០រៀល និងជាប់ពន្ធនាគាររហូតដល់៦ខែ)[83] មាត្រា២៩៤ (ការបំពានបញ្ញត្តិស្ដីពីការចុះបញ្ជីពាណិជ្ជកម្ម ឬការខកខានមិនបានតម្កល់ឯកសារទុកតាមលក្ខខណ្ឌរបស់ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសតាមមាត្រា ៤៣ និង៤៤ថ្មី នៃច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ដែលរងទោសពិន័យជាប្រាក់រហូតដល់ដប់លានរៀល និងជាប់ពន្ធនាគាររហូតដល់ប្រាំឆ្នាំ)[84] មាត្រា២៩៦ (ការខកខានមិនបានបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុទៅម្ចាស់ភាគហ៊ុន ត្រូវផ្តន្ទាទោសពិន័យជាប្រាក់រហូតដល់ដប់លានរៀល)[85] និងមាត្រា២៩៧ (ការខកខានមិនបានបញ្ជូនរបាយការណ៍ហិរញ្ញវត្ថុទៅឲ្យមន្ត្រីគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវផ្តន្ទាទោសពិន័យជាប្រាក់រហូតដល់ដប់លានរៀល)[86]នៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥។ គួរឲ្យកត់សម្គាល់ផងដែរ មាត្រាខាងលើបានកំណត់ទោសពិន័យជាប្រាក់ ឬទោសជាប់ពន្ធនាគារដែលត្រូវអនុវត្តចំពោះទាំង អ្នកប្រព្រឹត្តបទល្មើសផ្ទាល់ ឬអ្នកចូលរួមក្នុងការប្រព្រឹត្ត និងគ្រឹះស្ថានដែលមានអភិបាលជាអ្នកទទួលខុសត្រូវ ប្រសិនបើអភិបាលមិនបានបំពេញតួនាទីដោយស្មោះត្រង់ និងដើម្បីប្រយោជន៍ខ្ពស់បំផុតរបស់ក្រុមហ៊ុនស្របតាមស្មារតីនៃមាត្រា២៨៩ នៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម។

[82] ប្រកាសស្ដីពីការតម្កល់ប្រតិវេទន៍តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧ ប្រការ ៥។

[83] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ២៩០។

[84] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ២៩៤។

[85] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ២៩៦។

[86] ច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ២៩៧។

ច្បាប់ស្តីពីក្ស័យធនឆ្នាំ២០០៧ ក៏បានកំណត់យ៉ាងច្បាស់ពីកាតព្វកិច្ចរបស់អភិបាលនៃគ្រឹះស្ថានក្នុងការធានាឲ្យមានការដាក់បណ្តឹងសុំបើកសំណុំរឿងក្ស័យធន ក្នុងនាមគ្រឹះស្ថាន ក្នុងករណីដែលគ្រឹះស្ថានលែងមាន លទ្ធភាពបំពេញកាតព្វកិច្ចបង់ប្រាក់ដែលមានចំនួនលើសពីប្រាំលានរៀល ដែលការដាក់ពាក្យបណ្តឹងនេះ ត្រូវធ្វើឡើងក្នុងរយៈពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃកាលបរិច្ឆេទត្រូវសង។[87] ក្នុងករណីដែលអភិបាលមិនបានបំពេញកាតព្វកិច្ចធានាឲ្យមានការដាក់ពាក្យបណ្តឹងសុំបើកសំណុំរឿងក្ស័យធនស្របតាមមាត្រា៩(២) ខាងលើ ដោយចេតនា ឬដោយការធ្វេសប្រហែសក្តី អភិបាលត្រូវទទួលខុសត្រូវផ្ទាល់ខ្លួនរួមគ្នា ឬដាច់ដោយឡែកពីគ្នាចំពោះម្ចាស់បំណុលម្នាក់ ឬច្រើននាក់របស់កូនបំណុលលើការខូចខាតដែលកើតឡើងដោយផ្ទាល់ពីការខកខាននេះ។

បើក្រលេកទៅមើលមាត្រា ២៨ នៃក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាវិញ អភិបាលរបស់គ្រឹះស្ថានក៏អាចត្រូវបានផ្តន្ទាទោស ក្នុងករណីដែលអភិបាលបានប្រើប្រាស់តួនាទីរបស់ខ្លួនដើម្បីជំរុញឲ្យបុគ្គលិកប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ (ឧទាហរណ៍ បញ្ជាឲ្យបុគ្គលិកក្លែងឯកសារក្រុមហ៊ុនផ្សេងៗ)។[88] ក្នុងករណីកើតមានបទល្មើសប្រភេទនេះ ទាំងគ្រឹះស្ថាន និងអភិបាលផ្ទាល់ត្រូវទទួលរងការផ្តន្ទាទោសស្របទៅតាមបញ្ញត្តិច្បាប់ជាធរមាន។

### ៣.២.២. ការទទួលខុសត្រូវរបស់អភិបាលនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រោមក្របខណ្ឌច្បាប់គ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

បន្ថែមពីលើការទទួលខុសត្រូវដែលមានចែងក្នុងក្របខណ្ឌច្បាប់ពាណិជ្ជកម្ម ដូចដែលបានបកស្រាយខាងលើ ក្របខណ្ឌច្បាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានចែងកាន់តែលម្អិតអំពីការទទួលខុសត្រូវរបស់អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលមានលក្ខណៈតឹងរឹង និងដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ក្នុងករណីដែលអភិបាលមិនបានបំពេញតួនាទីឲ្យបានត្រឹមត្រូវ និងប្រុងប្រយ័ត្នទណ្ឌកម្មវិន័យ ទោសពិន័យជាប្រាក់ និងទោសជាប់ពន្ធនាគារ។

អភិបាលត្រូវទទួលរងទណ្ឌកម្មវិន័យ ប្រសិនបើអភិបាលរូបនោះមិនបានបំពេញតួនាទីរបស់ខ្លួនបានត្រឹមត្រូវ ឬអវត្តមានក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលជាប់ៗគ្នា ដោយគ្មានមូលហេតុត្រឹមត្រូវ។ ប្រការ ៤ នៃប្រកាសស្តីពីអភិបាលកិច្ចនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចែងថា

---

87 ច្បាប់ស្តីពីក្ស័យធន ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៧ មាត្រា ៩។

88 ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា ២៨។

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានដកចេញពីតំណែង ក្នុងករណីដែលបុគ្គលនោះ មិនបានចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលបីដងបន្តបន្ទាប់គ្នាដោយគ្មានមូលហេតុត្រឹមត្រូវ។[89] បន្ថែមពីលើទណ្ឌកម្មវិន័យដែលមានចែងក្នុងប្រកាសខាងលើ គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអាចកំណត់ទណ្ឌកម្មវិន័យដូចជាការព្រមានជាលាយលក្ខណ៍អក្សរ រហូតដល់ការបណ្តេញចេញពីតំណែង នៅក្នុងខចែង និងលក្ខខណ្ឌយោងរបស់ក្រុមប្រឹក្សាភិបាល។ សមាជិកក្រុមប្រឹក្សាភិបាលនីមួយៗ អាចត្រូវបានធ្វើការវាយតម្លៃប្រចាំឆ្នាំ ដោយគណៈកម្មការតែងតាំង និងផ្តល់តម្លៃការដែលដឹកនាំដោយអភិបាលឯករាជ្យ ហើយទណ្ឌកម្មវិន័យអាចត្រូវបានដាក់ដោយផ្អែកតាមលទ្ធផលនៃការវាយតម្លៃជាក់ស្តែង។[90]

លើសពីនេះទៅទៀត អភិបាលក៏អាចទទួលរងទណ្ឌកម្ម តាមរយៈទណ្ឌកម្មវិន័យដែលធនាគារជាតិនៃកម្ពុជាអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងករណីដែលគ្រឹះស្ថាននោះមិនបានគ្រប់គ្រង ឬអនុវត្តសកម្មភាពអាជីវកម្ម អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងតាមការណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ មាត្រា៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឆ្នាំ១៩៩៩ ចែងថា ប្រសិនបើគ្រឹះស្ថានប្រតិស្រុតបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ ឬបទបញ្ជាស្តីពីសកម្មភាពរបស់ខ្លួន ឬប្រសិនមិនបានធ្វើតាមអធិបញ្ជា អាជ្ញាធរអាណាព្យាបាលអាចសម្រេចដាក់ទណ្ឌកម្មវិន័យណាមួយដូចជា ការព្រមាន ការស្តីបន្ទោស ការព្យួរមុខងារបណ្តោះអាសន្ន ឬការបញ្ឈប់ពីការងារចំពោះអ្នកដឹកនាំម្នាក់ ឬច្រើននាក់ និងទណ្ឌកម្មវិន័យផ្សេងៗទៀត។[91] ផ្អែកតាមមាត្រា ៥២ ខាងលើនេះ អភិបាលនឹងត្រូវបានព្យួរការងារ ឬត្រូវបានបញ្ឈប់ពីការងារដោយធនាគារជាតិនៃកម្ពុជា ប្រសិនបើគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលខ្លួនបំពេញការងារ បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

អភិបាលដែលត្រូវបានបណ្តេញចេញពីតំណែង ដោយសារតែការបំពេញតួនាទីមិនបានត្រឹមត្រូវ ឬមកពីអវត្តមានជាច្រើនដងជាប់ៗគ្នា ឬត្រូវបានបញ្ឈប់ដោយអាជ្ញាធរអាណាព្យាបាល នឹងមិនអាចត្រូវបានតែងតាំងជាអភិបាលសារជាថ្មីសម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុណាមួយទេ ព្រោះថាប្រវត្តិនៃការបណ្តេញចេញនឹងត្រូវបានពិនិត្យ និងពិចារណាដោយធនាគារជាតិនៃកម្ពុជា នៅពេលដែលពិនិត្យពាក្យស្នើសុំតែងតាំង។

[89] ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ប្រការ ៤។

[90] ប្រកាសស្តីពីអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ប្រការ ៩។

[91] ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ មាត្រា ៥២។

ក្រៅពីទណ្ឌកម្មវិន័យដូចដែលបានបកស្រាយខាងលើ អភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវទទួលរងទណ្ឌកម្មខាងព្រហ្មទណ្ឌ (ទោសពិន័យជាប្រាក់ និងទោសជាប់ពន្ធនាគារ) ក្នុងករណីដែលគ្រឹះស្ថានដែលអភិបាលបានបម្រើការងារបានប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៩ និងមាត្រា ៤៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

យោងតាមមាត្រា ៩ និងមាត្រា១៤ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្រៅពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាប័ណ្ណពីអាជ្ញាធរអាណាព្យាបាល នីតិ-បុគ្គល ឬរូបវន្តបុគ្គលណាក៏ដោយ ត្រូវបានហាមឃាត់មិនឲ្យយកប្រតិបត្តិការធនាគារធ្វើជាអាជីវកម្មប្រក្រតីទេ។[92] ក្នុងន័យនេះ នីតិបុគ្គល ឬរូបវន្តបុគ្គលដែលធ្វើប្រតិបត្តិការធនាគារដោយគ្មានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នឹងត្រូវផ្តន្ទាទោសស្របទៅតាមបញ្ញត្តិនៃមាត្រា ៥៥ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ក្នុងករណីនេះ អភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ អាចជាប់ពាក់ព័ន្ធ និងទទួលរងទោសពិន័យជាប្រាក់ និងទោសជាប់ពន្ធនាគារដោយផ្ទាល់ផងដែរ ព្រោះថា ក្នុងនាមជាគណៈគ្រប់គ្រងជាន់ខ្ពស់របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ស្របតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងច្បាប់គ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវទទួលខុសត្រូវធានាឲ្យមានក្នុងការចុះបញ្ជី និងស្នើសុំអាជ្ញាប័ណ្ណប្រកបអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធ និងត្រូវធានាពីអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ចំណែកឯមាត្រា ៤៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឆ្នាំ ១៩៩៩ ចែងថា ចំពោះបុគ្គលដែលចូលរួម ទៅក្នុងឋានៈណាក៏ដោយ នៅក្នុងការអភិបាល ការដឹកនាំ ការកាន់កាប់ ការត្រួតពិនិត្យផ្ទៃក្នុង ឬពីខាងក្រៅនៃគ្រឹះស្ថានចំណុះច្បាប់នេះ ឬចំពោះបុគ្គលឯទៀតដែលធ្វើការងារឲ្យគ្រឹះស្ថានចំណុះច្បាប់នេះ មិនត្រូវបរិហារបញ្ចេញប្រាប់ដល់ជនណាក៏ដោយនូវព័ត៌មានដែលមានចរិតសម្ងាត់លើសេចក្តីប្រកាស ហេតុការណ៍ សារលិខិត ឬអត្ថន័យនៃឯកសារគណនេយ្យ ឬរដ្ឋបាលដែលខ្លួនបានដឹងតាមរយៈមុខងាររបស់ខ្លួន។[93] យោងតាមមាត្រានេះ អភិបាលមានកាតព្វកិច្ចរក្សាការសម្ងាត់នៃព័ត៌មានផ្សេងៗ ដែលខ្លួនបានដឹង ឬទទួលបានក្នុងពេលបម្រើការងារជាអភិបាលរបស់គ្រឹះស្ថាន ជាពិសេសព័ត៌មានអតិថិជន។ ជាទូទៅ

[92] ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ មាត្រា ៩។

[93] ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ មាត្រា ៤៧។

កាតព្វកិច្ចរក្សាការសម្ងាត់នេះ ត្រូវបន្តមានសុពលភាពរហូត ទោះបីជាក្រោយពេលដែលអភិបាលរូបនោះបានលាឈប់ ឬត្រូវបានបញ្ឈប់ពីការងារហើយក៏ដោយ។

ការបំពានបញ្ញត្តិនៃមាត្រា ៩ និងមាត្រា ៤៧ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុខាងលើ ទាំងគ្រឹះស្ថាន ឬអភិបាលផ្ទាល់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារពីមួយឆ្នាំ ដល់ប្រាំឆ្នាំ និងពិន័យជាប្រាក់ពីប្រាំលានរៀល រហូតដល់ពីររយហាសិបលានរៀល ឬទណ្ឌកម្មតែមួយក្នុងចំណោមទណ្ឌកម្មទាំងពីរ។[94]

ក្រៅពីនេះ អភិបាលក៏ត្រូវអាចត្រូវបានផ្តន្ទាទោសផងដែរ ក្នុងករណីដែលអភិបាលមិនចូលរួមសហការជាមួយអាជ្ញាធរអាណាព្យាបាល ដូចជា មិនឆ្លើយតបនឹងការសុំព័ត៌មានរបស់អាជ្ញាធរអាណាព្យាបាល មានចេតនា ផ្តល់ព័ត៌មានក្លែងក្លាយដល់អាជ្ញាធរអាណាព្យាបាល ឬបង្កឧបសគ្គដល់ការត្រួតពិនិត្យដោយអាជ្ញាធរអាណាព្យាបាល ដែលក្នុងករណីនេះ អភិបាលអាចត្រូវជាប់ពន្ធនាគាររហូតដល់ប្រាំឆ្នាំ និងពិន័យជាប្រាក់រហូតដល់ដប់លានរៀល ឬទទួលទណ្ឌកម្មណាមួយក្នុងចំណោមទណ្ឌកម្មទាំងពីរ។[95]

ពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម អភិបាលមានតួនាទីសំខាន់ និងមានការទទួលខុសត្រូវខ្ពស់ក្នុងការធានាថា គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ មានគោលនយោបាយ និងនីតិវិធីគ្រប់គ្រាន់ និងមានប្រព័ន្ធត្រួតពិនិត្យដែលមានប្រសិទ្ធភាព ក្នុងការការពារមិនឲ្យឧក្រិដ្ឋជនប្រើប្រាស់គ្រឹះស្ថានសម្រាប់លាងសម្អាតប្រាក់កខ្វក់របស់ពួកគេ នឹងទប់ស្កាត់ហិរញ្ញប្បទានភេរវកម្ម។

យោងតាមមាត្រា ២៩ថ្មី១ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ការសម្អាតប្រាក់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់ប្រាំឆ្នាំ និងពិន័យជាប្រាក់រហូតដល់មួយរយលានរៀល ឬរហូតដល់ស្មើនឹងតម្លៃមូលនិធិឬទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការសម្អាតប្រាក់។[96] ប្រសិនបើអភិបាលចូលរួមប្រព្រឹត្ត ទោះបីក្រោមរូបភាពណាមួយក៏ដោយ (ជួយសម្រួលដល់អតិថិជន ដោយផ្ទាល់ក្នុងការបើកគណនី ឬផ្ទេរប្រាក់ក្នុងគោលបំណងសម្អាតប្រាក់ ឬបញ្ជាបុគ្គលិកឲ្យជួយសម្រួលដល់អតិថិជន) អភិបាលរូបនោះនឹងត្រូវបានផ្តន្ទាទោសស្របបញ្ញត្តិនៃមាត្រា ២៩ថ្មី១ ខាងលើ។

---

[94] ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ មាត្រា ៥៥ (២)។

[95] ច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ មាត្រា ៥៥(៣)។

[96] ច្បាប់ស្តីពីវិសោធនកម្មមាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣ មាត្រា ២៩ថ្មី១។

ទណ្ឌកម្មទាក់ទងនឹងហិរញ្ញប្បទានភេរវកម្ម មានលក្ខណៈធ្ងន់ធ្ងរជាងបទល្មើសសម្អាតប្រាក់។ បុគ្គលណាដែលមានចេតនាផ្តល់ ឬប្រមូលមូលនិធិ ឬផ្តល់លទ្ធភាពប្រើប្រាស់ទ្រព្យសម្បត្តិ ធនធាន ឬសេវាកម្មដោយផ្ទាល់ ឬដោយប្រយោលដល់ភេរវករ ឬអង្គការភេរវកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីដប់ឆ្នាំដល់ម្ភៃឆ្នាំ។[97] ក្នុងករណីនេះ ប្រសិនបើ អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បានប្រើប្រាស់តួនាទីរបស់ខ្លួនផ្តល់ហិរញ្ញប្បទានដោយចេតនាដល់ភេរវករ ឬអង្គការភេរវករ អភិបាលរូបនោះនឹងត្រូវបានផ្តន្ទាទោសស្របតាមបញ្ញត្តិ នៃមាត្រា២៩ថ្មី មាត្រា៧ នៃច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

គួរឲ្យកត់សម្គាល់ផងដែរថា អភិបាលនៃគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ អាចត្រូវបានបកស្រាយថាមានជាប់ពាក់ព័ន្ធនឹងបទល្មើសសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ប្រសិនបើអភិបាលបានអនុម័ត និងដាក់ឲ្យប្រើប្រាស់ដោយចេតនានូវគោលនយោបាយដែលមានចរិតជួយសម្រួលដល់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

## ៤. សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក ក្របខណ្ឌច្បាប់ពាណិជ្ជកម្ម និងក្របខណ្ឌច្បាប់គ្រប់គ្រងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបានផ្តល់សិទ្ធិ និងកាតព្វកិច្ចយ៉ាងទូលំទូលាយ ដល់អភិបាលក្នុងការគ្រប់គ្រង និងដឹកនាំគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ អភិបាលមានតួនាទីសំខាន់ និងការទទួលខុសត្រូវខ្ពស់ក្នុងការធានាឲ្យមានការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន និងលើកកម្ពស់អភិបាលកិច្ចល្អ ដើម្បីពង្រឹងភាពរឹងមាំ និងធានាស្ថេរភាពរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

ដូច្នេះ អភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ គួរព្យាយាមស្វែងយល់ និងយល់ដឹងឲ្យបានច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនដែលបានកំណត់ក្រោមក្របខណ្ឌច្បាប់ពាណិជ្ជកម្ម និងក្របខណ្ឌច្បាប់អនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ អភិបាលរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវខិតខំបំពេញការងាររបស់ខ្លួនដោយស្មោះត្រង់ និងប្រុងប្រយ័ត្ន និងត្រូវដាក់ចេញនូវយុទ្ធសាស្ត្រ គោលនយោបាយ និងនីតិវិធីនានា ដែលចាំបាច់

[97] ច្បាប់ស្តីពីវិសោធនកម្មមាត្រា ៣ មាត្រា ២៩ និងមាត្រា ៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣ មាត្រា ២៩ថ្មី៧។

សម្រាប់ធានាឲ្យមានការអនុវត្តនូវតួនាទីរបស់ខ្លួនស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ព្រោះថាការខកខានមិនបានបំពេញតួនាទីណាមួយរបស់ខ្លួន ឬការអនុវត្តដោយបំពានច្បាប់ និងបទប្បញ្ញត្តិណាមួយអាចធ្វើឲ្យអភិបាលទទួលរងទណ្ឌកម្មធ្ងន់ធ្ងរដែលរួមមានទណ្ឌកម្មវិន័យ ទោសពិន័យជាប្រាក់ រហូតដល់ទោសជាប់ពន្ធនាគារ។

# សកម្មភាពរបស់គណៈមេធាវី

# ១.ទំនាក់ទំនងជាតិ និងអន្តរជាតិ

## ១.១.ទំនាក់ទំនងជាតិ

### សិក្ខាសាលាស្តីពី មុខងារនីតិកម្មនិងការងារកែទម្រង់របស់រាជរដ្ឋាភិបាល

នាព្រឹកថ្ងៃអង្គារ ១៣កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០១៩ លោកមេធាវី ព្រហ្ម វិចិត្រសុភា សមាជិកក្រុមប្រឹក្សាគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា អមដោយថ្នាក់ដឹកនាំមន្ត្រីជំនាញ០៥រូបបានចូលរួមសិក្ខាសាលា ក្រោមប្រធានបទស្តីពី "មុខងារនីតិកម្ម និងការងារកែទម្រង់របស់រាជរដ្ឋាភិបាល" ដែលបាន ប្រព្រឹត្តធ្វើនៅសណ្ឋាគារ សុខា រាជធានីភ្នំពេញ។






## ១.២.ទំនាក់ទំនងអន្តរជាតិ

លោកប្រធានគណៈមេធាវីកម្ពុជា ដឹកនាំប្រតិភូចូលរួមសន្និសីទប្រចាំឆ្នាំរបស់គណៈមេធាវី អន្តរជាតិ ដែលប្រព្រឹត្តទៅនៅទីក្រុង SEOUL (សេអ៊ូល) នៃសាធារណរដ្ឋកូរ៉េខាងត្បូង

លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានដឹកនាំប្រតិភូគណៈមេធាវីចូលរួមសន្និសីទប្រចាំឆ្នាំរបស់គណៈមេធាវីអន្តរជាតិ ដែលប្រព្រឹត្តទៅនៅទីក្រុង SEOUL (សេអ៊ូល) នៃសាធារណរដ្ឋកូរ៉េខាងត្បូង ចាប់ពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៩ ។ ការចូលរួមរបស់គណៈមេធាវីកម្ពុជាក្នុងសន្និសីទប្រចាំឆ្នាំរបស់គណៈមេធាវីអន្តរជាតិនៅពេលនេះ គឺដើម្បីបង្កើនទំនាក់ទំនងជាមួយនឹងគណៈមេធាវីអន្តរជាតិដទៃទៀត ដើម្បីលើកកម្ពស់វិជ្ជាជីវៈមេធាវី និងការពិគ្រោះយោបល់គ្នាទៅវិញទៅមក រួមទាំងការចូលរួមសិក្សារៀនសូត្រការវិវឌ្ឍន៍ទៅលើវិស័យច្បាប់នានា ដែលកំពុងមានការវិវឌ្ឍន៍រីកចម្រើន ។ ដោយឡែក គណៈប្រតិភូនៃគណៈមេធាវីកម្ពុជាបានជួបពិភាក្សាជាមួយគណៈមេធាវីសាធារណរដ្ឋកូរ៉េខាងត្បូង ដើម្បីផ្លាស់ប្តូរយោបល់ និងស្វែងរកកិច្ចសហប្រតិបត្តិការដើម្បីការពារសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាដែររស់នៅប្រទេសកូរ៉េ ។ គណៈប្រតិភូនៃគណៈមេធាវីកម្ពុជា ក៏បានជួបប្រាស្រ័យទាក់ទងផងដែរជាមួយ គណៈមេធាវីសហរដ្ឋអាមេរិក និងគណៈមេធាវីហុងកុង រួមទាំងគណៈមេធាវីបណ្តាលប្រទេសមួយចំនួនទៀត ដើម្បីពង្រឹងទំនាក់ទំនងក្នុងនាមគណៈមេធាវីកម្ពុជាជាមួយ និងគណៈមេធាវីបណ្តាលប្រទេសទាំងនោះ។



## លោកមេធាវី សួន វិសាល ដឹកនាំគណៈប្រតិភូគណៈមេធាវីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ធ្វើទស្សនកិច្ចសិក្សា ដើម្បីស្វែងយល់ពីការគាំទ្រការប្រើប្រាស់ស្លាកសញ្ញាស្អាតស្អំ និង សុចរិតភាពនៅនាយកដ្ឋានការពារសិទ្ធិអ្នកប្រើប្រាស់ និងប្រជុំពិភាក្សាការងារជាមួយគណៈមេធាវីថៃ

នៅថ្ងៃទី ២៦ រហូតដល់ថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០១៩ លោកមេធាវី សួន វិសាល បានដឹកនាំគណៈប្រតិភូគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ទៅធ្វើទស្សនកិច្ចសិក្សាដើម្បីស្វែងយល់ពីការពីការគាំទ្រ ការប្រើប្រាស់ស្លាកសញ្ញាស្អាតស្អំ និង សុចរិតភាពនៅនាយកដ្ឋានការពារសិទ្ធិអ្នកប្រើប្រាស់ និងគណៈមេធាវីនៃព្រះរាជាណាចក្រថៃ។

គោលបំណងនៃទស្សកិច្ចសិក្សា និងប្រជុំពិភាក្សាការងារនេះមាន៖

-ស្វែងយល់ពីការគាំទ្រការប្រើប្រាស់ស្លាកសញ្ញាស្អាតស្អំ និង សុចរិតភាព នៅនាយកដ្ឋានការពារសិទ្ធិអ្នកប្រើប្រាស់។

-ស្វែងរកការសហការជាដៃគូ រវាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងគណៈមេធាវីនៃព្រះរាជាណាចក្រថៃ លើការផ្តល់សេវាផ្លូវច្បាប់ដល់ប្រជាពលរដ្ឋខ្មែរដែលរស់នៅព្រះរាជាណាចក្រថៃ។

ក្នុងដំណើរទស្សនកិច្ចនេះ ក្រោមការឧបត្ថមដោយក្រុមហ៊ុន AIYARA Planet លោកប្រធានគណៈមេធាវី ក៏បានដឹកនាំគណៈប្រតិភូទៅធ្វើទស្សនកិច្ចសិក្សានៅក្រុមហ៊ុន AIYARA Planet ដែលជាក្រុមហ៊ុនផ្តោតសំខាន់ទៅលើការគាំទ្រការប្រើប្រាស់ស្លាកសញ្ញាស្អាតស្អំ និង សុចរិតភានេះផងដែរ។



## គណៈមេធាវីកម្ពុជាបានពិភាក្សាជាមួយសហព័ន្ធមេធាវីជប៉ុន

នារសៀលថ្ងៃសុក្រ ៨រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីកម្ពុជា បានជួបជជែកពិភាក្សាការងារជាមួយសមភាគីសហព័ន្ធមេធាវីជប៉ុនដឹកនាំដោយលោក Naoshi Sato ជាអនុប្រធានគណៈកម្មាធិការទំនាក់ទំនងអន្តរជាតិ។ កិច្ចពិភាក្សាបានផ្តោតសំខាន់លើគម្រោងសិទ្ធិទទួលបាននូវយុត្តិធម៌ (Access to Justice) ដែលនៅក្នុងនោះផ្តោតសំខាន់លើ៖

- ការផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋតាមមូលដ្ឋាន
- ការស្រាវជ្រាវ និងផ្សព្វផ្សាយអត្ថបទច្បាប់នៅក្នុងព្រឹត្តិបត្រគណៈមេធាវី
- ការចែករំលែក បទពិសោធការងាររវាងគណៈមេធាវីតំបន់រួមមានគណៈមេធាវីវៀតណាម និងឡាវ តាមរយៈការរៀបចំសិក្ខាសាលានៅក្នុងប្រទេសនីមួយៗ។

លោក Naoshi Sato បានលើកឡើងថា គណៈមេធាវីកម្ពុជាជាស្ថាប័នគំរូមួយដែលមានការយកចិត្តទុកដាក់ក្នុងផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋមូលដ្ឋាន និងមានប្រតិភូមេធាវីនៅតាមបណ្តាសាលាដំបូងរាជធានី ខេត្ត ទូទាំងប្រទេសសម្រាប់ពលរដ្ឋទទួលបាននូវសេវាកម្មមេធាវី ដោយមិនយកកម្រៃ។ លោកក៏បានសង្កត់ធ្ងន់ផងដែរថាគម្រោងនៃសិទ្ធិទទួលបានយុត្តិធម៌របស់សហព័ន្ធមេធាវីជប៉ុន នឹងយកគណៈមេធាវីកម្ពុជាជាគំរូក្នុងការអនុវត្តគម្រោងនៅក្នុង តំបន់។ គម្រោងនេះនឹង ពង្រីកនៅតាមបណ្តាប្រទេសផ្សេងៗទៀតក្នុងតំបន់អាស៊ាន។ នៅក្នុងកិច្ចជជែកពិភាក្សានេះលោកប្រធានគណៈមេធាវីក៏បានបង្ហាញពីតម្រូវការចាំបាច់របស់គណៈមេធាវីនាពេលបច្ចុប្បន្ន ជាពិសេស សេវាយុត្តិធម៌សង្គម ការផ្សព្វផ្សាយច្បាប់ និងកង្វះនូវថវិកាសម្រាប់ជួយរឿងក្តីក្រីក្រដែលសេវាចាំបាច់ដល់ប្រជាពលរដ្ឋតាមមូលដ្ឋាន។

លោក Naoshi Sato បានឆ្លើយតបថា លោកនឹងយកតម្រូវការរបស់គណៈមេធាវីទៅជជែក ពិភាក្សាជាមួយភាគីពាក់ព័ន្ធរបស់ខ្លួនបន្តទៀត។

កិច្ចប្រជុំបានបញ្ចប់នៅ ក្រោមបរិយាកាសយោគយល់ និងស្និទ្ធស្នាល។





## ២.ការផ្សព្វផ្សាយច្បាប់តាមរយៈសិក្ខាសាលា

សិក្ខាសាលា " ការអនុវត្តបែបកុមារមេត្រីក្នុងនីតិវិធីយុត្តិធម៌ដើម្បីការការពារជនរងគ្រោះ នៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ"

នៅថ្ងៃពុធ ១៣ កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៩ លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានឡើងថ្លែងចំណាប់អារម្មណ៍ តំណាងគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងអង្គសិក្ខាសាលា ស្តីពី "ការអនុវត្តបែបកុមារមេត្រីក្នុងនីតិវិធីយុត្តិធម៌ដើម្បីការការពារជនរងគ្រោះ នៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ"។

លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវី បានថ្លែងថា អង្គសិក្ខាសាលានេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់មេធាវី និងសហភាតា អ្នកអនុវត្តច្បាប់ពាក់ព័ន្ធក្នុងការបង្កើនចំណេះដឹងពាក់ព័ន្ធ នឹងការអនុវត្តវិធានព្រហ្មទណ្ឌលើកុមារដែលប្រព្រឹត្តល្មើសនឹងច្បាប់ ដោយអនុវត្តនូវយន្តការកុមារមេត្រី។

ក្នុងចំណាប់អារម្មណ៍នោះផងដែរ លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវីកម្ពុជា សង្ឃឹម និងជឿជាក់ថា អង្គភាពពាក់ព័ន្ធ តុលាការ នគរបាលយុត្តិធម៌ មេធាវី អង្គការសង្គមស៊ីវិល និងក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀតនឹងសហការចាប់ដៃគ្នាយ៉ាងស្អិតរមួតធ្វើកិច្ចការងារនេះអោយកាន់តែប្រសើរជាងមុន ក្នុងបុព្វហេតុកុមារជាទំពាំងស្នងឫស្សី កុមារជាសសរទ្រូងនៃប្រទេសជាតិ និងកុមារជាចលករនៃការអភិវឌ្ឍជាតិ។

គួសបញ្ជាក់ថា សិក្ខាសាលានេះមានគោលបំណង បង្កើនចំណេះដឹងស្តីអំពីការអនុវត្តបែបកុមារមេត្រីក្នុងការធ្វើការជាមួយកុមារដែលចូលរួមនីតិវិធីស្វែងរកយុត្តិធម៌ និងស្វែងយល់ការអនុវត្តល្អពីភាគីធ្វើការពាក់ព័ន្ធសំដៅការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារជាចម្បង ដែលសិក្ខាសាលានេះប្រព្រឹត្តធ្វើឡើងនៅកាំបូឌីយ៉ាណា រាជធានីភ្នំពេញ ក្រោមកិច្ចសហការរវាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការ APLE ដោយមានការចូលរួមពីមេធាវី តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ តំណាងសាលាឧទ្ធរណ៍ និងអង្គការនានា ព្រមទាំងដៃគូសហការផ្សេងៗ ។





## ៣.កិច្ចប្រជុំបុគ្គលិក

### ត្រួតពិនិត្យការងារ និងលទ្ធភាពការងារតាមនាយកដ្ឋាន

នាសៀល ថ្ងៃសងអង្គារ ០៤រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី ក្រោមអធិបតីភាព លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការបានដឹកនាំកិច្ចប្រជុំបុគ្គលិកដើម្បីត្រួតពិនិត្យការងារ និងសកម្មភាពការងារតាមនាយកដ្ឋាននីមួយៗសម្រាប់រៀបចំមហាសន្និបាតប្រចាំឆ្នាំ២០១៩ ។

កិច្ចប្រជុំនេះមានការចូលរួមពី អគ្គលេខាងធិការរង ប្រធាន និងអនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ ព្រមទាំងបុគ្គលិកគណៈមេធាវីផងដែរ។


គណៈមេធាវី
នៃព្រះរាជាណាចក្រកម្ពុជា
THE BAR ASSOCIATION
OF


គណៈមេធាវី
នៃព្រះរាជាណាចក្រកម្ពុជា
THE BAR ASSOCIATION
OF

## កិច្ចប្រជុំបុគ្គលិកគណៈមេធាវីប្រចាំខែ

កិច្ចប្រជុំបុគ្គលិកគណៈមេធាវីប្រចាំខែ និងការត្រួតពិនិត្យការងារសម្រាប់មហាសន្និបាតរបស់គណៈមេធាវី ឆ្នាំ២០១៩

នៅព្រឹកថ្ងៃពុធ ០៦រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការ នៃគណៈមេធាវីកម្ពុជាបានដឹកនាំកិច្ចប្រជុំបុគ្គលិកដើម្បីត្រួតពិនិត្យការងារប្រចាំខែ និងការត្រួតពិនិត្យការងារសម្រាប់មហាសន្និបាត របស់គណៈមេធាវីប្រចាំឆ្នាំ២០១៩ ។






## ពិធីបើកបវេសនកាលវគ្គសិក្សាសិស្សមេធាវីជំនាន់ទី១៧ ឆ្នាំសិក្សា ២០១៩-២០២០

នាព្រឹកថ្ងៃចន្ទ ៤កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានប្រារព្ធ ពិធីបើកបវេសនកាលវគ្គសិក្សាសិស្សមេធាវីជំនាន់ទី១៧ ឆ្នាំសិក្សា២០១៩-២០២០ ក្រោម អធិបតីភាពលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុង ពិធីនេះក៏មានការចូលរួមពីប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី និងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវី ព្រមទាំងសិស្សមេធាវីជំនាន់ទី ១៧ ដោយក្នុងនោះមាន សិស្សមេធាវីជាស្រ្តី ២៨ លើចំនួនសិស្សមេធាវីសរុប ៦១ នាក់ ដែលជាការកំណត់សម្គាល់ របស់គណៈមេធាវីគឺមានសិស្សជាស្រ្តីច្រើនជាងជំនាន់មុនៗ។

ក្នុងពិធីសំណេះសំណាលនេះលោកប្រធានគណៈក៏មានមតិផ្តាំផ្ញើ និងជម្រុញលើក ទឹកចិត្តដល់ សិស្សមេធាវីទាំងអស់អោយខិតខំរៀនសូត្រ មករៀនអោយទៀងទាត់ និងយក ចិត្តទុកដាក់ក្នុងការសិក្សា ដើម្បីក្លាយជាមេធាវីប្រកបដោយវិជ្ជាជីវៈ និងមានសមត្ថភាពខ្ពស់ នាពេលអនាគត។





## សិក្ខាសាលា " ការតស៊ូមតិការពារក្តីព្រហ្មទណ្ឌ និងជំនាញផ្នែកច្បាប់"

នៅថ្ងៃសុក្រ ១១កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ១២ ខែកក្កដា ឆ្នាំ២០១៩ គណៈមេធាវីបានសហការជាមួយនឹងស្ពានយុត្តិធម៌អន្តរជាតិ (International Bridges to Justice) បានរៀបចំសិក្ខាសាលាក្រោម ប្រធានបទស្តីពី " ការតស៊ូមតិការពារក្តីព្រហ្មទណ្ឌ និងជំនាញផ្នែកច្បាប់" ក្រោមអធិបតីភាពរបស់លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី នៅទីស្នាក់ការរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។



## សិក្ខាសាលា "បណ្តាញផ្សព្វផ្សាយក្រមបរិស្ថាន

នៅព្រឹកថ្ងៃសុក្រ ៩កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១៩ តំណាងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានចូលរួមសិក្ខាសាលាក្រោមប្រធានបទ "បណ្តាញផ្សព្វផ្សាយក្រមបរិស្ថាន" The Environmental Code Network's Dissemination ។ គោលបំណងនៃសិក្ខាសាលានេះ គឺដើម្បី ទ្រទ្រង់ ការធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់បរិស្ថាន ការលើកកម្ពស់ការកសាងសមត្ថភាព មន្ត្រីអនុវត្ត ទូទាំងប្រទេស ដើម្បីត្រៀមចូលរួមការអនុវត្តក្រមបរិស្ថាននាពេល អនាគត និងចូលរួមលើកកម្ពស់ប្រសិទ្ធភាពនៃការអភិវឌ្ឍ ច្បាប់ និងបទដ្ឋានគតិយុត្តបរិស្ថាន។ សិក្ខាសាលនេះប្រព្រឹត្តនៅសណ្ឋាគារ ឌីកាំបូឌីយ៉ា រាជធានីភ្នំពេញ ដោយមានការការចូលរួមពី តំណាង ក្រសួងបរិស្ថាន តំណាងគណៈមេធាវី អង្គការ USAID និង UNDP និងដៃគូសហការផ្សេងៗ។





## សិក្ខាសាលាក្រោមប្រធានបទ "ការផ្តល់សេវាច្បាប់ដោយមិនយកប្រាក់កម្រៃ និងយុទ្ធសាស្ត្រដោះស្រាយរឿងក្តីការជួញដូរមនុស្ស"

នៅព្រឹកថ្ងៃពុធ ៧កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាបានសហការជាមួយអង្គការ PILnet និងអង្គការ Liberty Shared បានរៀបចំសិក្ខាសាលាក្រោមប្រធានបទ "ការផ្តល់សេវាច្បាប់ដោយមិនយកប្រាក់កម្រៃ និងយុទ្ធសាស្ត្រដោះស្រាយរឿងក្តីការជួញដូរមនុស្ស" ដែលបានប្រព្រឹត្តធ្វើនៅសណ្ឋាគារ ឌីកាំបូឌីយ៉ា រាជធានីភ្នំពេញ។

លោកមេធាវី ព្រហ្ម វិចិត្រអក្ខរា អគ្គលេខាធិការគណៈមេធាវីកម្ពុជាបានអញ្ជើញឡើងថ្លែងសុន្ទរកថាបើក សិក្ខាសាលា ដោយមានការចូលរួមពីមេធាវីខ្មែរ តំណាងតុលាការ អង្គការ

ជាតិ និងអន្តរជាតិ ព្រមទាំងដៃគូសហការផ្សេងៗ។ លោកមេធាវី ព្រហ្ម វិចិត្រអក្ខរាបាន សង្កត់ធ្ងន់ថា អង្គសិក្ខាសាលានេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់មេធាវី និងអ្នកអនុវត្តច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ក្នុងការបង្កើនចំណេះដឹងពាក់ព័ន្ធនឹងការផ្តល់សេវាច្បាប់ដោយមិនយកប្រាក់កម្រៃ និងយុទ្ធសាស្ត្រដោះស្រាយរឿងក្តីការជួញដូរមនុស្ស។

គួសបញ្ជាក់ថា សិក្ខាសាលានេះមានរយៈពេលពីរថ្ងៃគឺថ្ងៃទី៧ រហូតដល់ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៩ ដែលប្រព្រឹត្តធ្វើឡើងនៅសណ្ឋាគារ ឌីកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។



## ៤.កិច្ចប្រជុំគណៈកម្មការជំនាញ

### កិច្ចប្រជុំការងារកិច្ចការរដ្ឋប្បវេណីលើកទី ៨

នាថ្ងៃអង្គារ ១២កើត ខែភទ្របទឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១៩ នៅទីស្នាក់ការគណៈមេធាវី គណៈកម្មការកិច្ចការរដ្ឋប្បវេណីបើកកិច្ចប្រជុំការងារកិច្ចការរដ្ឋប្បវេណីលើកទី ៨ ដែលមានរបៀបវិរៈដូចខាងក្រោម ៖

-មូលហេតុនៃការខកខានកិច្ចប្រជុំនាពេលកន្លងមក

-ព័ត៌មានផ្សេងៗពីសមាជិកក្រុមការងារ

- ការរៀបចំផែនការសម្រាប់ការផ្សព្វផ្សាយច្បាប់

-ការសិក្សាមេរៀនស្តីពីការប្រាក់ធម្មតាការប្រាក់សមាសនិងការប្រាក់ឃើតយ៉ាវ

-ការរៀបចំសិក្ខាសាលាប្រចាំឆ្នាំ

កិច្ចប្រជុំការងារនិងការពិភាក្សាផ្លាស់ប្តូរយោបល់នេះបានបញ្ចប់ដោយភាពស្និទ្ធស្នាលនិងភាតរភាព។




## កិច្ចប្រជុំ ប្រធាន អនុប្រធាន គណៈកម្មការជំនាញទាំង៥

នារសៀលថ្ងៃពុធ ៦រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា បានរៀបចំកិច្ចប្រជុំ ប្រធាន អនុប្រធាន គណៈកម្មការជំនាញទាំង៥ រួមមាន គណៈកម្មការកិច្ចការសិទ្ធិមនុស្ស និងច្បាប់អន្តរជាតិ គណៈកម្មការកិច្ចការការងារ គណៈកម្មការកិច្ចការពាណិជ្ជកម្ម គណៈកម្មការកិច្ចការរដ្ឋប្បវេណី និងគណៈកម្មការកិច្ចការព្រហ្មទណ្ឌ លើកទី១ ក្រោមការដឹកនាំប្រជុំដោយលោកមេធាវី គង់ សំអុន ប្រធាននាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ លើរបៀបវារៈចំនួន៤៖ (១) ការណែនាំប្រធាននាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ ដែលត្រូវបានតែងតាំងថ្មី (២) ការផ្សព្វផ្សាយច្បាប់តាមវិទ្យុ និងទូរទស្សន៍ (៣) ការពិភាក្សាលើប្រធានបទ ដែលត្រូវផ្សព្វផ្សាយតាមគណៈកម្មការជំនាញ និងការ

ស្រាវជ្រាវសម្រាប់ការបោះពុម្ព ក្នុងព្រឹត្តិបត្រមេធាវី និង(៤) ផ្សេងៗ ដើម្បីធ្វើបច្ចុប្បន្នភាពការងាររបស់គណៈកម្មការជំនាញនីមួយៗ។




## ៥. ការផ្សព្វផ្សាយតាមទូរទស្សន៍

នៅក្នុងមួយត្រីមាននេះ គណៈមេធាវីបានចូលរួមយ៉ាងសកម្មក្នុងការផ្សព្វផ្សាយ តាមរយៈវិទ្យុ និងទូរទស្សន៍ ដែលនៅក្នុងនោះមានវាគ្មិន លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី និងលោកមេធាវីគង់ សំអុន ប្រធាននាយកដ្ឋានស្រាវជ្រាវបោះពុម្ព និងផ្សព្វផ្សាយ។ ប្រធានបទសំខាន់កិច្ចពិភាក្សាច្បាប់នោះរួមមាន តួនាទីមេធាវី និងការវិភាគច្បាប់ទាក់ទងនឹងបទល្មើសដែលកើតមានឡើងនៅក្នុងសង្គម។

*ប្រធានបទអំពី តួនាទីមេធាវី*

ការផ្សាយរបស់ទូរទស្សន៍ BTV Cambodia: ជជែកពីច្បាប់ វគ្គ១ និង វគ្គ២ - តួនាទីមេធាវី និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

https://www.facebook.com/1426087464349805/posts/2261781214113755?s=100003743345531&v=e&sfns=xmo




*កិច្ចជជែកច្បាប់ និងការវិភាគច្បាប់លើបទល្មើសដែលកើតមាននៅក្នុងសង្គម*

ជជែកពីច្បាប់ "ការកាត់ទោស ១៦៦ឆ្នាំលើ ជនជាប់ចោទ ពេជ្រ សូណៃត " “ជជែកពីច្បាប់” ប្រធានបទ៖“បទឃាតកម្មនិងបទឃាតកម្មគិតទុកជាមុន”

"ករណីឃាតកម្ម ប្រព្រឹត្តិដោយ លោក ឡាយវណ្ណៈ អតីតអភិបាលខេត្តតាកែវ និងបងប្រុស "



## ៦. ផ្សេងៗ

### ប្រធានគណៈមេធាវីអនុញ្ញាតឲ្យនិស្សិតសាកលវិទ្យាល័យមកពីបណ្តាខេត្តចូលជួបដើម្បីស្វែងយល់ពីគណៈមេធាវី

នាថ្ងៃសុក្រ ១ កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ពុទ្ធសករាជ ២៥៦៣ ត្រូវនឹងថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៩ នៅទីស្នាក់ការគណៈមេធាវី លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឲ្យ សាស្ត្រាចារ្យ និងសមណនិស្សិត និស្សិតពូកែ ផ្នែក នីតិសាស្ត្រ មកពីសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (UME) និស្សិតសាកលវិទ្យាល័យបាត់ដំបង (UBB) នៃខេត្តបាត់ដំបង និងសាកលវិទ្យាល័យសៅស៍អ៊ីសថ៍អេយសៀ (USEA) សៀមរាប ចំនួន៣០ រូប ដើម្បីធ្វើទស្សនៈកិច្ចសិក្សាស្វែងយល់ និងទទួលបានបទពិសោធន៍អំពីតួនាទី និងភារៈកិច្ចរបស់គណៈមេធាវី។ នៅក្នុងកិច្ចសំណេះសំណាលនេះ លោកមេធាវី សួន វិសាល ក៏បានធ្វើបទបង្ហាញអំពីវឌ្ឍនភាពនៃការងាររបស់គណៈមេធាវីដែលសម្រេចបាន និងបានផ្តល់ឱកាសសម្រាប់សមននិស្សិត និស្សិតសួរសំណួរដើម្បីជជែកពិភាក្សាផងដែរ។



## គណៈកម្មការព្រឹត្តិបត្រ

| | |
|---|---|
| ១-ឯកឧត្តម សួន វិសាល | ចាងហ្វាងការផ្សាយ |
| ២-លោកមេធាវី កុយ នាម | និពន្ធនាយក |
| ៣-លោកមេធាវី លីវ សុវណ្ណា | លេខាធិការ |

## នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ

| | |
|---|---|
| ១-លោកមេធាវី គង់ សំអុន | ប្រធាននាយកដ្ឋាន |
| ២-លោកមេធាវី ម៉ៃ ច័ន្ទសត្យា | អនុប្រធាននាយកដ្ឋាន |
| ៣-លោក ឃឹម ច័ន្ទធឿន | អនុប្រធាននាយកដ្ឋាន |
| ៤-លោកមេធាវី វ៉ា សំរិត | ប្រធានការិ. ព្រឹត្តិបត្រ និងបោះពុម្ព |
| ៥-លោក ខន សុខេង | ប្រធានការិ.ស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ |
| ៦-លោក ថា ប៊ុនថៃ | ប្រធានការិ.ព័ត៌មានវិទ្យា |
| ៧- លោក ស្រេង សីហាប៊ុននុត | ជំនួយការ ការិ.ព័ត៌មានវិទ្យា |
| ៨- កញ្ញា តាន់ ចរណី | បណ្ណារក្ស |

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លោកមេធាវី សារិន ដេណូវ៉ា

DFDL

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា